00238317

D39/3/25

### នៅចំពោះមុខអង្គបុរេជំនុំជម្រះ
### អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# ចំពោះបញ្ហាស្តីអំពីបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់នឹង ដីកាដំណោះស្រាយលើរូបលោក កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ០២)

## *សារណារបស់អ្នកមិនមែនជាភាគីក្នុងរឿងក្តី*

*ដាក់ជូនដោយមជ្ឈមណ្ឌលដើម្បីសិទ្ធិមនុស្ស និងពហុច្បាប់(Center for Human Rights and Legal Pluralism) នៃសាកលវិទ្យាល័យ McGill University*

*ទីក្រុង Montreal (កេបិក) ប្រទេសកាណាដា*

McGill Centre for Human Rights and Legal Pluralism

Centre sur les droits de la personne et le pluralisme juridique de McGill

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 07 / 11 / 2008
ម៉ោង (Time/Heure): 09 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 07 / NOV / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

00238318

D99/3/28

## ១. ក្រុមអ្នកមិនមិនជាភាគីក្នុងរឿងក្តី

១. **មជ្ឈមណ្ឌល McGill ដើម្បីសិទ្ធិមនុស្ស និងពហុច្បាប់** (The McGill Center for Human Rights and Legal Pluralism - CHRLP) ជាស្ថាប័ន ដែលកំពុងដាក់សារណានេះក្នុងឋានៈជាអ្នកជូនយោបល់តុលាការ តបតាមការអញ្ជើញរបស់អង្គបុរេជំនុំជម្រះក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨។ មជ្ឈមណ្ឌល CHRLP គឺជាស្ថាប័នកណ្តាលសម្រាប់ការសិក្សាស្រាវជ្រាវពីនាវានុវត្តិន៍ច្បាប់ និងអន្តរវិស័យផ្សេងទៀត និងសម្រាប់វេទិកាពិភាក្សា ព្រមទាំងការផ្សព្វផ្សាយលើបញ្ហាទាំងឡាយស្តីពីសិទ្ធិមនុស្ស និងពហុនៃច្បាប់។ គោលបំណងសំខាន់របស់មជ្ឈមណ្ឌល CHRLP គឺសំដៅជំរុញបន្ថែមទៀតនូវសហសិក្សាអន្តរមុខវិជ្ជាលើទិដ្ឋភាពសង្គម សីលធម៌ នយោបាយ និងទស្សនវិជ្ជាដ៏ស្មុគស្មាញស្តីពីសិទ្ធិមនុស្ស។ ចាប់តាំងពីឆ្នាំ២០០៤មក មជ្ឈមណ្ឌលបានដំណើរការមជ្ឈមណ្ឌលផ្តល់យោបល់ និងបណ្តុះបណ្តាលប្រចាំតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនដើម្បីផ្តល់ការសហការគាំទ្រដល់តុលាការពិសេសនេះ។

២. **មហាវិទ្យាល័យច្បាប់នៃសកលវិទ្យាល័យ McGill** មានកិត្តិស័ព្ទល្បីល្បាញជាយូរមកហើយក្នុងស្នាដៃស្រាវជ្រាវ និងបង្រៀនក្នុងវិស័យសិទ្ធិមនុស្ស។ មហាវិទ្យាល័យនេះក៏មានលក្ខណៈពិសេសដោយឡែកពីគេផងដែរចំពោះការស្រាវជ្រាវ និងការបង្រៀនជាពីរភាសា និងតាមប្រព័ន្ធច្បាប់ពីរផ្សេងគ្នាក្នុងពេលតែមួយ ហើយមហាវិទ្យាល័យក៏មានឈ្មោះបោះសម្លេងជាយូរមកហើយដែរក្នុងវិស័យច្បាប់ប្រៀបធៀប ពហុប្រពៃណីនៃច្បាប់ និងពហុភាពនៃច្បាប់។

៣. **សាស្ត្រាចារ្យ René** Provost គឺជានាយកស្ថាបនិកនៃមជ្ឈមណ្ឌល CHRLP ដែលបានដឹកនាំបង្កើតមជ្ឈមណ្ឌលនេះនៅរដូវស្លឹកឈើជ្រុះនាឆ្នាំ២០០៥។ លោកសាស្ត្រាចារ្យបង្រៀនលើមុខវិជ្ជាជាច្រើនក្នុងវិស័យសិទ្ធិមនុស្ស ពហុភាពសង្គម រួមទាំងនីតិអន្តរជាតិស្តីពីសិទ្ធិមនុស្សនីតិមនុស្សធម៌អន្តរជាតិ និងនីតិអន្តរជាតិសាធារណៈ។ លោកសាស្ត្រាចារ្យជាអ្នកនិពន្ធសៀវភៅច្បាប់មនុស្សធម៌ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ (បោះពុម្ពផ្សាយដោយសកលវិទ្យា

ល័យ Oxford ឆ្នាំ២០០២) ដែលជាសៀវភៅច្បាប់ដ៏ល្បី ដែលផ្តោតលើទំនាក់ទំនងទៅវិញទៅមករវាងច្បាប់ទាំងពីរនេះ។

៤. **សាស្ត្រាចារ្យ** Payam Akhavan បង្រៀន និងស្រាវជ្រាវក្នុងវិស័យនីតិអន្តរជាតិសាធារណៈ: នីតិព្រហ្មទណ្ឌអន្តរជាតិ និងយុត្តិធម៌អន្តរកាល ដោយផ្តោតជាពិសេសលើសិទ្ធិមនុស្ស និងពហុវប្បធម៌ ការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាម កំណែទម្រង់អង្គការសហប្រជាជាតិ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។ លោកសាស្ត្រាចារ្យធ្លាប់ធ្វើជាទីប្រឹក្សាច្បាប់ដំបូងបង្អស់ឱ្យការិយាល័យព្រះរាជអាជ្ញា នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី (ICTY) និងរ៉ាន់ដា (ICTR)។

៥. **សាស្ត្រាចារ្យ** Frederic Megret គឺជាសាស្ត្រាចារ្យដឹកនាំស្រាវជ្រាវនៅកាណាដាលើច្បាប់ស្តីពីសិទ្ធិមនុស្ស និងពហុភាពច្បាប់នៅមហាវិទ្យាល័យច្បាប់McGill ហើយលោកក៏ជានាយកមជ្ឈមណ្ឌលផ្តល់ប្រឹក្សា និងការបណ្តុះបណ្តាលMcGillប្រចាំតុលាការពិសេសសម្រាប់ប្រទេសសេរាឡេអូនផងដែរ។ លោកសាស្ត្រាចារ្យជាអ្នកនិពន្ធសៀវភៅ *តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា* (បោះពុម្ពជាភាសាបារាំង នៅPedone ឆ្នាំ២០០២) ហើយលោកក៏ជាសមាជិកម្នាក់នៃក្រុមប្រតិភូបារាំងក្នុងសន្និសីទទីក្រុងរ៉ូម ដែលនាំទៅដល់ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ។

៦. **កញ្ញា** Maureen T. Duffy, **លោក** Carlos Ivan Fuentes, **លោក** Amar Khoday, និង**លោកស្រី** Melissa Martins Casagrande គឺជាបេក្ខជនថ្នាក់បណ្ឌិតនៅមហាវិទ្យាល័យច្បាប់McGill។ អ្នកទាំងនេះជាសមាជិកមជ្ឈមណ្ឌល CHRLP ហើយក៏អតីតអ្នកស្រាវជ្រាវឱ្យមជ្ឈមណ្ឌលផ្តល់ប្រឹក្សា និងបណ្តុះបណ្តាល McGill ប្រចាំតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនដែរ។ **លោក** Malcolm Dort **លោក**Jake Hirsch-Allen និង**កញ្ញា** Sophie Tremblay គឺជានិស្សិតកំពុងសិក្សាច្បាប់ថ្នាក់ក្រោយឧត្តមសិក្សា L.L.B/B.C.L ហើយ**លោក** Jake Hirsch-Allen គឺជានាយកប្រតិបត្តិបច្ចុប្បន្នប្រចាំមជ្ឈមណ្ឌលផ្តល់ប្រឹក្សា និងបណ្តុះបណ្តាលMcGill។ **កញ្ញា** Sebastien Jodoin គឺជានិស្សិតបញ្ចប់ការសិក្សាកម្មវិធី BCL/LLB

00238320

D99/3/15

ពីមហាវិទ្យាល័យ McGill ហើយក៏ជាអតីតសមាជិកមជ្ឈមណ្ឌលMcGill ប្រចាំតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូនដែរ។ គាត់ធ្លាប់បម្រើការងារនៅអង្គជំនុំជម្រះទី៣ នៃតុលាការ ICTR និងអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY។

## ២. សម្រង់សង្ខេប

៧. ទំនួលខុសត្រូវចំពោះការចូលរួមក្នុងទម្រង់ណាមួយនៃផែនការរួម មានអត្ថិភាពក្នុងច្បាប់អន្តរជាតិយ៉ាងហោចណាស់ក៏តាំងពីសង្គ្រាមលោកលើកទីពីរមកម្ល៉េះ។[1] ករណីដែលល្បីថ្មីៗនេះស្តីពីទស្សនទាននៃសហកម្មឧក្រិដ្ឋកម្មរួម (JCE)មាននៅក្នុងសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ICTY ក្នុងករណី*ព្រះរាជអាជ្ញា ទល់នឹង ថាឌិក*។[2] សំណុំរឿងព្រហ្មទណ្ឌអន្តរជាតិជាច្រើនក្រោយៗមកទៀតផ្អែកលើការបកស្រាយក្នុងករណីនេះ ដើម្បីកំណត់ពីទម្រង់នៃការចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ។ យុត្តិសាស្ត្រភាគច្រើន ដែលតុលាការបានលើកមកពីចារណាដើម្បីកាត់សេចក្តីលើករណី*ថាឌិក*នេះក៏មានអត្ថិភាពមុនអំឡុងពេល ដែលស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) ឆ្នាំ១៩៧៥ ដល់១៩៧៩ដែរ។ ហេតុដូច្នេះហើយ ការសម្រេចរបស់អ.វ.ត.កថាសហកម្មឧក្រិដ្ឋកម្មរួមអាចអនុវត្តបានក្នុងរយៈពេលដែលពាក់ព័ន្ធនោះ នឹងស្របគ្នាជាមួយច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។

៨. ការពិនិត្យមើលឡើងវិញនូវទ្រឹស្តីអនុវត្ត និងយុត្តិសាស្ត្រជាតិ និងអន្តរជាតិនេះបញ្ជាក់ឲ្យឃើញនូវភាពអាចអនុវត្តបានចំពោះទម្រង់នៃការចូលរួមនេះក្នុងសំណុំរឿងនៅអ.វ.ត.ក។ លទ្ធផលនៃការពិនិត្យមើលឡើងវិញបញ្ជាក់ថា ទម្រង់នៃការទទួលខុសត្រូវនេះអាចអនុវត្តបានយ៉ាងត្រឹមត្រូវ ហើយជាពិសេស *ទម្រង់ទី៣* ដែលជាទម្រង់ពង្រីកបន្ថែមអាចត្រូវបានកំណត់និយមន័យតាមលក្ខណៈមួយដែលមិនប៉ះពាល់ដល់សិទ្ធិជនជាប់ចោទ។

---

[1] នៅក្នុងយុត្តាធិការជាតិមួយចំនួន ទំនួលខុសត្រូវក្នុងទម្រង់នេះមានអត្ថិភាពជាយូរឆ្នាំមកហើយមុនសង្គ្រាមលោកលើកទី២ *សូមមើល* កំណត់សម្គាល់ខាងក្រោម។

[2] *រដ្ឋអាជ្ញា ទល់នឹង Dusko Tadic* IT-94-1-A សាលដីកាលើបណ្តឹងឧទ្ធរណ៍ (ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩) (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី)

00238321

D99/3/25

## ៣.	ចំណោទបញ្ហា

៩.	តើវឌ្ឍនភាពនៃទ្រឹស្ដីសហកម្មឧក្រិដ្ឋកម្មរួម និងការវិវត្តនិយមន័យនៃទម្រង់នៃការទទួលខុសត្រូវនេះបង្ហាញឲ្យឃើញថាទ្រឹស្ដីនេះអាចអនុវត្តនៅចំពោះមុខអ.វ.ត.កបានដែរឬទេ បើគិតពិចារណាពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ ១៩៧៩?

## ៤.	សហកម្មឧក្រិដ្ឋកម្មរួមមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវក្នុងច្បាប់អន្តរជាតិយ៉ាងហោចណាស់តាំងឆ្នាំ១៩៤៥

១០.	គោលការណ៍ *គ្មានទោសបើគ្មានច្បាប់ចែង (nullum crimen sine lege)* គឺជាគោលការណ៍គ្រឹះនៃច្បាប់ព្រហ្មទណ្ឌផង និងជាទម្លាប់អនុវត្តជាទូទៅមួយក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិផង។ គោលការណ៍នេះទាមទារជាចាំបាច់ថា ជនម្នាក់អាចត្រូវបានគេរកឃើញថាមានពិរុទ្ធចំពោះបទឧក្រិដ្ឋមួយបាន លុះត្រាតែអំពើប្រព្រឹត្តរបស់ជននោះត្រូវបានគេចាត់ទុកថាជាអំពើល្មើសច្បាប់នៅក្នុងពេលប្រព្រឹត្តនោះ។[3] គោលការណ៍នេះអនុវត្តបានចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មផ្ទាល់ផង និងទម្រង់ផ្សេងទៀតនៃការចូលរួមផង។

១១.	ដូច្នេះ យោងតាមអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការICTY ក្នុងករណី*Hadzihasanovic* ចំណុចសំខាន់នៃបញ្ហាគឺស្ថិតនៅលើអំពើជាក់ស្ដែងរបស់ជនជាប់ចោទ នៅក្នុងពេលប្រព្រឹត្តបទល្មើស៖

[3] *សូមមើល សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស* ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ មហាសន្និបាទអង្គការសហប្រជាជាតិ សេចក្ដីសម្រេចលេខ ២១៧ក (៣) ឯកសារ A/811 (១៩៤៨) មាត្រា១១(២)។ *កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ 993។ *ពិធីសារបន្ថែមទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩*និង *ឧបសម្ព័ន្ធទៅនឹងការការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ (ពិធីសារទី២)* ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧។ *លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ* ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨។

00238322

D99/3/25

ដើម្បីបំពេញឲ្យបានត្រឹមត្រូវតាមគោលការណ៍ *គ្មានទោសបើគ្មានច្បាប់ចែង* គេត្រូវតែរកឲ្យឃើញថា ជនដែលណាម្នាក់នោះអាចប្រមើលមើលឃើញជាមុន និងអាចយល់បានដោយងាយថា អំពើជាក់ស្តែងរបស់ខ្លួននេះអាចត្រូវបានផ្តន្ទាទោសនៅក្នុងពេលនៃការប្រព្រឹត្តនោះ។ ទោះបីអំពើរបស់ខ្លួននោះអាចមានទោសដោយសារតែការធ្វើ ឬការខកខានមិនបានធ្វើក្តី ឬទោះបីអំពើនោះអាចនាំឲ្យមានទំនួលខុសត្រូវខាងព្រហ្មទណ្ឌ ឬទំនួលខុសត្រូវខាងវិន័យ ឬទណ្ឌកម្មដទៃទៀតក្តី ក៏មិនជាសំខាន់ណាស់ណាឡើយ។[4]

១២. មានកន្ទ្បាមសំណួរពីរដែលចោទឡើង ពាក់ព័ន្ធនឹងការអនុវត្តគោលការណ៍ *គ្មានទោសបើគ្មានច្បាប់ចែង* នៅក្នុងបរិបទនៃការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនេះ។ កន្ទ្បាមបញ្ហាទី១ទាក់ទងនឹង ថាតើអំពើដែលត្រូវបានចោទប្រកាន់តាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួមនេះមានទោសឬទេនៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិនៅពេលបទល្មើសនេះត្រូវបានប្រព្រឹត្ត? អ្នកសិក្សាជាន់ខ្ពស់ជាច្រើន បានរិះគន់ការរកឃើញរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការICTYថា សហកម្មឧក្រិដ្ឋកម្មរួមមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវមួយនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលចោទប្រកាន់លើសំណុំរឿងនេះ។ អ្នកសិក្សាជាន់ខ្ពស់ទាំងនោះបានលើកឡើងថា យុត្តិសាស្ត្រដែលកំពុងប្រើនេះមិនបានផ្តល់ការគាំទ្រទាល់តែសោះដល់ទ្រឹស្តីអនុវត្តចំពោះសហកម្មឧក្រិដ្ឋកម្មរួម ដូចដែលបានបកស្រាយពន្យល់ដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍។[5]

១៣. កន្ទ្បាមបញ្ហាទី២ ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវនៃភាពដែលអាចមើលឃើញជាមុន និងភាពអាចយល់បានដោយងាយនៃគោលការណ៍*គ្មានទោសបើគ្មានច្បាប់ចែង*។ ដូចបានបញ្ជាក់ខាងលើ

---

[4] រដ្ឋអាជ្ញា ទល់នឹង *Hadzihasanovic* សំណុំរឿងលេខ IT-01-47-PT សេចក្តីសម្រេចលើបណ្តឹងរួមលើយុត្តាធិការ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌទី៦២។

[5] លោក Allison Marston និង លោកស្រី Jenny S. Martinez *ការចូលរួមប្រព្រឹត្តខុស: សហកម្មឧក្រិដ្ឋកម្មរួម ទំនួលខុសត្រូវថ្នាក់លើ និងវឌ្ឍនភាពនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (ឆ្នាំ២០០៥)*។ លោក Machteld Boot *អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម: គ្មានទោសបើគ្មានច្បាប់ចែង និងបញ្ហាយុត្តាធិការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ* (Antwerpen: Intersentia, ២០០២)។

លក្ខខណ្ឌតម្រូវពីភាពដែលអាចមើលឃើញជាមុននឹងអាចបំពេញតាមបាន ប្រសិនបើគេអាចបង្ហាញឱ្យឃើញថាអំពើនោះពិតជាអាចមើលដឹងជាមុន ហើយងាយយល់ចំពោះជនដែលដល់បានថា អំពើជាក់ស្តែងរបស់ខ្លួនត្រូវមានទោសក្នុងពេលប្រព្រឹត្តនោះ។ វិធីសាស្ត្រអនុវត្តនៅក្នុងបណ្តាតុលាការពិសេសបានសន្មត់ថាលក្ខខណ្ឌតម្រូវទាំងពីរនេះត្រូវបានបំពេញ ប្រសិនបើអំពើនោះត្រូវបានគេរកឃើញថាមានទោសនៅក្រោមច្បាប់អន្តរជាតិ។[6] ការសន្មត់នេះនាំទៅដល់ការអនុវត្តយ៉ាងតឹងរ៉ឹងនៃទ្រឹស្តីនៃការមិនដឹងច្បាប់មិនអាចជាការដោះសារ (ignorantia juris non excusat)។

១៤. ចំពោះសំណុំរឿងយើងនេះ លក្ខខណ្ឌតម្រូវនៃគោលការណ៍ *គ្មានទោសបើគ្មានច្បាប់ចែង* នឹងអាចបំពេញតាមបាន ប្រសិនបើសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានគេរកឃើញថាធ្លាប់បានទទួលស្គាល់ជា ទម្រង់នៃការចូលរួមមួយនៅក្រោមច្បាប់អន្តរជាតិ ឬច្បាប់ជាតិនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ (១៩៧៥ ដល់ ១៩៧៩)។ គេនឹងអាចបង្ហាញឱ្យឃើញថា សហកម្មឧក្រិដ្ឋកម្មរួមគឺជាទ្រឹស្តីអនុវត្តមួយនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវបានយកមកប្រើក្នុងករណីជាច្រើនពាក់ព័ន្ធនឹងសង្គ្រាមលោកលើទី២។ មិនតែប៉ុណ្ណោះ ការពិចារណាទៅលើយុត្តាធិការគំរូក្នុងស្រុកមួយចំនួនក៏គាំទ្រការសន្និដ្ឋានថា សហកម្មឧក្រិដ្ឋកម្មរួមជាគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលមានអត្ថិភាពរួចហើយនៅក្នុងអំឡុងពេលពាក់ព័ន្ធ។

## ១. ការលេចឡើងនូវការទទួលស្គាល់ជាអន្តរជាតិនូវទំនួលខុសត្រូវបុគ្គលចំពោះការប្រព្រឹត្តបទឧក្រិដ្ឋរួមក្នុងបណ្តាតុលាការយោធាក្រោយសង្គ្រាមលោកលើកទី២

១៥. នៅក្នុងសំណុំរឿង *Tadic* អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការICTY បានផ្អែកជាសំខាន់ទៅលើយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ ក្នុងការបង្ហាញឱ្យឃើញថា

[6] *សូមមើលឧទាហរណ៍* ករណី រដ្ឋអាជ្ញា ទល់នឹង Martic សំណុំរឿងលេខ IT-95-11-A សាលដីកាលើបណ្តឹងសារទុក្ខ យោបល់ជំទាស់របស់លោកចៅក្រម Schomburg ស្តីអំពីទំនួលខុសត្រូវព្រហ្មទណ្ឌបុគ្គលរបស់លោក Milan Martic (ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨) (តុលាការ ICTY)។

00238324

D99/3/25

"សញ្ញាណនៃគម្រោងការរួមគឺជាទម្រង់មួយនៃបទផ្សំគំនិត ដែលត្រូវបានបង្កើតឡើងយ៉ាងច្បាស់និងរឹងមាំក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។"[7] ការគាំទ្រជាក់ស្តែងភាគច្រើនលើអត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានទាញចេញពីសេចក្តីសន្និដ្ឋានរបស់ខាងអយ្យការ នៅក្នុងតុលាការយោធា ឬទាញចេញពី"កំណត់សម្គាល់លើសំណុំរឿង"របស់គណៈកម្មាធិការឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គការសហប្រជាជាតិ ជាជាងការទាញចេញពីសេចក្តីសម្រេចរបស់ចៅក្រមជំនុំជម្រះ ដែលជាទូទៅសេចក្តីសម្រេចទាំងនោះមានលក្ខណៈសង្ខេបពេក។ នាពេលបច្ចុប្បន្ន សេចក្តីសម្រេចភាគច្រើនក៏ពិបាករកបានដែរ ហើយតុលាការICTY បានពឹងផ្អែកយ៉ាងខ្លាំងទៅលើការបកប្រែភាសាក្រៅផ្លូវការ ដែលជាទូទៅមិនអាចផ្ទៀងផ្ទាត់បាន។ សហកម្មឧក្រិដ្ឋកម្មរួម ទម្រង់ទី១ ("ទម្រង់មូលដ្ឋាន) ឬទម្រង់ទី២ ("ទម្រង់ជាប្រព័ន្ធ) ទទួលបានការគាំទ្រយ៉ាងច្បាស់បំផុតពីបណ្តាតុលាការយោធាទាំងអស់ បើទោះបីអង្គហេតុទាំងឡាយក្នុងសំណុំរឿងដែលបានយោងដើម្បីគាំទ្រដល់ទម្រង់ទី៣ ("ទម្រង់ពង្រីកបន្ថែម") មិនសូវដូចមែនទែនទៅនឹងស្ថានភាព (scenarios) ដែលទម្រង់ទី៣នេះតែងជាប់ពាក់ព័ន្ធជាមួយក៏ដោយ។ ទោះបីយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើទី២ ដែលបានដកស្រង់បញ្ចូលក្នុងករណី *Tadic* មិនសូវជាប្រាកដប្រជាដូចយុត្តិសាស្ត្រជាតិក៏ដោយ ទម្រង់នីមួយៗនៃសហកម្មឧក្រិដ្ឋកម្មរួមនេះមានការគាំទ្រមួយចំនួន ពីក្នុងចំណោមយុត្តិសាស្ត្ររបស់បណ្តាតុលាការយោធាក្រោយសង្គ្រាមលោកលើកទី២។

១៦. ករណី *Schonfeld* ដែលបានលើកមកដើម្បីគាំទ្រដល់សហកម្មឧក្រិដ្ឋកម្ម*ទម្រង់ទី១* នោះគឺជាឧទាហរណ៍គាំទ្របឋមមួយ។ ការគាំទ្រល្អបំផុតចំពោះសហកម្មឧក្រិដ្ឋកម្មរួមស្ថិតនៅលើទឡ្ហីករណ៍របស់ព្រះរាជអាជ្ញាថា បទប្បញ្ញត្តិ៨ (ii) នៃរាជក្រម ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៤៥ គួរយកមកអនុវត្តក្នុងករណីនេះ៖

---

[7] ថាឌិក កំណត់ជើងទំព័រទី២ខាងលើ កថាខណ្ឌ២២០។ ចំពោះការវិភាគរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍លើករណីនេះ សូមមើល កថាខណ្ឌ១៩៥-២១៩។

នៅពេលណាមានភស្តុតាងបញ្ជាក់ថា ឧក្រិដ្ឋកម្មសង្គ្រាមមួយកើតមានឡើងដោយសារការប្រព្រឹត្តរួមគ្នារបស់ផ្នែកនៃអង្គភាព ឬក្រុមមនុស្សណាមួយ នោះភស្តុតាងដែលផ្តល់ឲ្យចំពោះការចោទប្រកាន់ណាមួយពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសមាជិកណាម្នាក់នៃអង្គភាព ឬក្រុមនោះអាចចាត់ទុកថាជាភស្តុតាងសង្ស័យបឋមនៃទំនួលខុសត្រូវរបស់សមាជិកម្នាក់ៗ នៅក្នុងអង្គភាព ឬក្រុមនោះចំពោះឧក្រិដ្ឋកម្មនោះ។[8]

១៧. ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នេះគ្រាន់តែជាវិធាននៃភស្តុតាងមួយប៉ុណ្ណោះ ហើយភាគច្រើននៃការពិភាក្សារបស់តុលាការគឺស្ថិតនៅជុំវិញការជួយនិងជំរុញ ដោយគ្រាន់តែយោងបន្ថែមទៅលើ "គំរោងការរួម" ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ចៅក្រមជំនុំជម្រះបានដកស្រង់វិធានមួយចេញពីច្បាប់សារធាតុរបស់ប្រទេសអង់គ្លេសដើម្បីជំនួសវិធាននៃភស្តុតាងនេះ ដែលបង្ហាញពីភាពដូចគ្នាខ្លះរវាងបទដ្ឋានសារធាតុ និងបទដ្ឋានភស្តុតាង។ គាត់បានបកស្រាយពន្យល់ច្បាប់ស្តីពីគម្រោងការរួមដូចខាងក្រោម៖

ប្រសិនបើជនច្រើនរូបរួមគ្នាដើម្បីសម្រេចនូវគោលបំណងខុសច្បាប់មួយ ឬដើម្បីសម្រេចគោលបំណងស្របច្បាប់តាមមធ្យោបាយខុសច្បាប់ ហើយជនម្នាក់ក្នុងចំណោមជនទាំងនោះបានសម្លាប់មនុស្សនៅក្នុងពេលកំពុងអនុវត្តនូវគោលបំណងនោះ វាគឺជាអំពើមនុស្សឃាតរួមគ្នាចំពោះអ្នកដែលមានវត្តមាននោះ បើទោះបីតាមពិតទៅជនទាំងនោះបានជួយ ឬជំរុញ ឬមិនបានក្តី អោយតែការស្លាប់នោះបង្កឡើងដោយសមាជិកម្នាក់ នៃក្រុមជនទាំងនោះនៅក្នុងពេលខិតខំសម្រេចនូវវត្ថុបំណងរួមនៃការប្រមូលផ្តុំគ្នានោះ។ [9]

១៨. អង្គហេតុក្នុងការជំនុំជម្រះករណី *Almelo* បង្ហាញឲ្យឃើញពីស្ថានភាព(scenario) ដូចសហកម្មឧក្រិដ្ឋកម្មរួម ដែលក្នុងនោះមានជនបីនាក់ ម្នាក់ៗមានតួនាទីផ្សេងៗគ្នាក្នុងករណីបាញ់សម្លាប់ពីរ៖ ម្នាក់ជាអ្នកបាញ់សម្លាប់ ម្នាក់ជាអ្នកបញ្ជា និងជនទីបីនៅចាំនៅឯឡានដើម្បី

---

[8] សវនាការលើករណី Franz Schonfeld និងជនប្រាំបួននាក់ផ្សេងទៀត (១៩៤៦) របាយការណ៍ច្បាប់ទីXI នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមទី៦៤ ចំណុចទី៦៨។

[9] ដូចឯកសារខាងលើ។

D99/3/28

ទប់ស្កាត់កុំឱ្យមនុស្សដទៃចូលមកជិត។ ចៅក្រមកាត់សេចក្តី ដោយបានរកឃើញថាជនទាំងបីនាក់នោះបានដឹងនូវអ្វីដែលពួកគេបានធ្វើ និងបានដឹងថាជនម្នាក់ៗមានវត្តមានដើម្បីសម្លាប់ជនរងគ្រោះនោះ បានថ្លែងថា៖

> ប្រសិនបើជនទាំងនោះមានវត្តមាននៅជាមួយគ្នា ក្នុងពេលតែមួយចូលរួមក្នុងគម្រោងការរួមដែលខុសច្បាប់ ហើយជនម្នាក់ៗតាមមធ្យោបាយរៀងៗខ្លួនបានជួយសម្រេចបំណងរួមនៃអ្នកទាំងអស់គ្នានោះ ជនទាំងនោះត្រូវមានទោសស្មើៗគ្នាក្នុងគតិច្បាប់។[10]

ទោះបីជនជាប់ចោទទាំងអស់នោះត្រូវបានតុលាការរកឃើញថាមានកំហុសក៏ដោយ អ្នកដែលបានបញ្ជា ឬអ្នកដែលបានបាញ់សម្លាប់ត្រូវកាត់ទោសប្រហារជីវិត។ ចំណែកឯអ្នកដទៃទៀតត្រូវបានកាត់ទោសឱ្យជាប់គុកចំនួនដប់ប្រាំឆ្នាំ។[11] នេះគឺជាការចង្អុលបង្ហាញឱ្យឃើញពីភាពខុសគ្នានៃទោសទណ្ឌសមមាត្រទៅតាមតួនាទីរបស់បុគ្គលម្នាក់ៗ នៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម ប៉ុន្តែវាក៏បញ្ជាក់ផងដែរថាជនទាំងនោះសុទ្ធតែមានពិរុទ្ធ។

១៩. វឌ្ឍនភាពថ្មីៗនេះនៅចំពោះមុខតុលាការយោធាប្រទេសអ៊ីតាលីក៏មានការពាក់ព័ន្ធផងដែរទៅនឹងរយៈកាលដូចគ្នានេះ។ អតីតសមាជិកនៃកងយោធាអាឡឺម៉ង់ និងកងយោធាS.Sត្រូវបានកាត់ទោសចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តក្នុងអំឡុងសង្គ្រាមលោកលើកទី២។[12] ជនជាប់ចោទទាំងនោះត្រូវបានតុលាការរកឃើញថាមានកំហុស ចំពោះការចូលរួមរបស់ពួកគេម្នាក់ៗនៅក្នុងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តជាផ្លូវការ និងជាបន្តបន្ទាប់ដំណាលៗគ្នា។ នៅក្នុងករណីរបស់ *Nordhorm និង Seifert* តុលាការបានសង្កត់ធ្ងន់ទៅលើអង្គហេតុ ដែលថា

[10] *ការជំនុំជម្រះក្តីលើករណី Otto Sandrock និងជនបីនាក់ផ្សេងទៀត* (ករណី Almelo) (1945) របាយការណ៍ច្បាប់នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមទី៣៦។

[11] ដូចឯកសារខាងលើ ចំណុច៤១។

[12] រួមទាំងករណី Gerhard Sommer និងអ្នកដទៃ (២០០៥) និង ករណី Heinrich Nordhorn (2006) នៅតុលាការយោធាទីក្រុង La Spezia ករណី Michael Seifert (២០០) នៅតុលាការយោធា Verona និងករណី Siegfried Engel (១៩៩៩) នៅតុលាការ Torino។

ក្រិដ្ឋកម្មទាំងនោះត្រូវបានប្រព្រឹត្តឡើងតាមរយៈ“សកម្មភាពជាច្រើន ដែលបានអនុវត្តតាមគម្រោងការឧក្រិដ្ឋដូចគ្នា នៅក្នុងពេលស្របគ្នាជាមួយសមាជិកដទៃទៀតនៃក្រុមយោធាដែលមានបណ្តាស័ក្តដូចគ្នា។”[13] នៅក្នុងករណី *Sommer និងអ្នកដទៃទៀត* តុលាការយោធានៃទីក្រុង La Spezia បានរកឃើញថា មន្ត្រីយោធា១០រូបដែលបង្កើតបានជាផ្នែកមួយនៃយោធា S.S ត្រូវបានតុលាការរកឃើញថា “មានកំហុសពីបទផ្សំគំនិតក្នុងអំពើមនុស្សឃាតជាច្រើន ដោយសារពួកគេបានគិតទុក បង្កើតផែនការ និងអនុវត្តការសម្លាប់រង្គាលជនស៊ីវិល៥៦០នាក់។”[14]

២០. តុលាការក្នុងករណី *Tadic* បានលើកយកជំរុំប្រមូលផ្តុំ *Dachau* និង*Belsen* ដើម្បីគាំទ្រដល់ការដាក់ឱ្យទទួលខុសត្រូវក្រោមសហកម្មឧក្រិដ្ឋកម្មរួម *ទម្រង់ទី២* ដែលក្នុងករណីទាំងពីនេះ តុលាការសម្រេចឲ្យមន្ត្រីជាន់ខ្ពស់នៃជំរុំប្រមូលផ្តុំទាំងនេះទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងជំរុំរបស់ពួកគេ។ សេចក្តីសម្រេចករណី *Dachau* ដែលត្រូវបានលើកមកពិចារណាក្នុងករណី *Tadic* បានបង្ហាញឲ្យឃើញច្បាស់ថា *“នៅក្នុងជំរុំប្រមូលផ្តុំនេះមានប្រព័ន្ធអនុវត្តអំពើឃោរឃៅ និងសម្លាប់អ្នកជាប់ឃុំជាទូទៅមួយ ...... ហើយ ........ ជនជាប់ចោទបានដឹងថាប្រព័ន្ធនេះត្រូវបានអនុវត្តនៅក្នុងជំរុំនេះ .... ហើយដោយមានការចូលរួមយ៉ាងសកម្មពីខ្លួនផង។”* ការនេះត្រូវបានតុលាការសម្រេចចាត់ទុកថាជា “ការធ្វើទៅតាមគម្រោងការរួមមួយ ដែលរំលោភច្បាប់សង្គ្រាម និងច្បាប់អនុវត្តទូទៅនៅពេលសង្គ្រាម”។ តុលាការបានគូសបញ្ជាក់ថា “ជនទាំងអស់ ដែលបានចូលរួមនៅក្នុងគម្រោងការរួមដូចនោះត្រូវមានទោសក្នុងបទឧក្រិដ្ឋសង្គ្រាម បើទោះបីលក្ខណៈ និងវិសាលភាពនៃទោសទណ្ឌនៃការចូលរួមនោះអាចខុសៗគ្នាក្តី”។[15]

---

[13] តុលាការយោធា ក្រុង La Spezia ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៦ 50/2006 N.551/2002 R.G.N.R.N. 16/2006 R.G. DIB

[14] Rosa Dinusi “កិច្ចនីតិវិធីលើ Gerhard Sommer និងអ្នកដទៃទៀត តុលាការយោធា La Spezia សាលក្រមថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥” ក្នុងសៀវភៅកំណត់ហេតុប្រចាំឆ្នាំស្តីពីច្បាប់មនុស្សធម៌អន្តរជាតិ A. McDonald ឆ្នាំ២០០៥ (បោះពុម្ពផ្សាយដោយ សកលវិទ្យាល័យ Cambridge ឆ្នាំ២០០៧) ចំណុច ៤៦៥។

[15] ករណី ថាឌិក កំណត់ជើងទំព័រទី២ខាងលើ កថាខណ្ឌ២០២។

D99/3/25

២១. ជំរុំ *Belsen* មានលក្ខណៈស្រដៀងគ្នាដែរ។ សេចក្ដីសម្រេច ដែលតុលាការ ICTY លើកយកមកនោះ ទោះបីតុលាការទាញចេញពីទឡ្ហីករណ៍របស់រដ្ឋអាជ្ញាក្ដី ក៏វាតំណាងឱ្យការរកឃើញរបស់តុលាការយោធាថា៖

> គ្រប់ជនជាប់ចោទទាំងអស់ដែលបានជួលឱ្យមកធ្វើជាបុគ្គលិកនៅឯជំរុំ Auschwitz សុទ្ធតែបានដឹងថាប្រព័ន្ធមួយ និងអំពើមួយកំពុងត្រូវបានគេអនុវត្ត ហើយអំពើនោះ ទោះតាមមធ្យោបាយណាមួយក៏ដោយ គឺជាការបន្តលើការព្រមព្រៀងរួមមួយក្នុងការដំណើរការជំរុំនោះតាមមធ្យោបាយសាហាវព្រៃផ្សៃ ហើយអ្នកទាំងនោះនៅតែចូលរួមជាផ្នែកមួយនៃការអនុវត្តអំពើទាំងនោះ។ ពួកគេបានស្នើសុំតុលាការឱ្យពិចារណាអំពើរបស់បុគ្គលម្នាក់ៗ ដែលការនេះនាំឱ្យតុលាការរកឃើញត្រឹមតែបទល្មើសដែលពួកគេម្នាក់ៗប្រព្រឹត្តប៉ុណ្ណោះ ប៉ុន្តែដូចដែលភស្តុតាងបានបញ្ជាក់យ៉ាងច្បាស់ថា ជនល្មើសទាំងនេះបានប្រព្រឹត្តដោយចេតនា ជាផ្នែកមួយក្នុងការបន្តប្រព័ន្ធបែបនេះតទៅទៀត។ ពួកគេបានស្នើថា ប្រសិនបើរកឃើញថាពួកគេបានធ្វើដូច្នោះមែន នោះពួកគេម្នាក់ៗត្រូវតែទទួលខុសត្រូវលើអ្វីៗដែលបានកើតឡើង។[16]

ជាក់លាក់ជាងនេះទៅទៀត លក្ខណៈវិនិច្ឆ័យសម្រាប់សហកម្មឧក្រិដ្ឋកម្ម *ទម្រង់ទី២* ដែលបានស្នើឡើងដោយរដ្ឋអាជ្ញា និងយកមកប្រើដោយចៅក្រមជំនុំជម្រះក្នុងករណីជំរុំ *Belsen* ត្រូវបានលើកឡើងម្ដងទៀត និងសម្រេចយកមកប្រើក្នុងករណី *Tadic*។ លក្ខណៈវិនិច្ឆ័យទាំងនោះមានជាអាទិ៍“ទី(១) អត្ថិភាពនៃប្រព័ន្ធចាត់តាំងមួយដើម្បីធ្វើបាបជនជាប់ឃុំ និងដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដែលជាប់សង្ស័យ។ ទី(២) ការដឹងរបស់ជនជាប់ចោទពីលក្ខណៈទូទៅនៃប្រព័ន្ធនោះ និងទី(៣) ការដែលជនជាប់ចោទខ្លួនឯងតាមមធ្យោបាយណាមួយបានចូលរួមយ៉ាងសកម្មក្នុងការជំរុញការអនុវត្តនូវប្រព័ន្ធនោះ”។

២២. ករណីចុងក្រោយ ដែលតុលាការICTYបានលើកយកមកដើម្បីគាំទ្រដល់សហកម្មឧក្រិដ្ឋកម្ម *ទម្រង់ទី២* តាមពិតទៅ ករណីនេះគាំទ្រខ្លាំងដល់ការអនុវត្តគោលលទ្ធិ *ជួយ និងទំនុកបម្រុង*។

---

[16] ករណី Joseph Kramer និងជន៤៤នាក់ដទៃទៀត (ការជំនុំជម្រះលើជំរុំ Belsen) (ឆ្នាំ១៩៤៥) របាយការណ៍ច្បាប់ II នៃការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមទី១ នៅចំណុច១២១។ ករណី ថាឌិក កំណត់សម្គាល់ទី២ កថាខណ្ឌ២០០២។

D99/3/25

ដូច្នេះ ករណី *Mulka* គួរមានការញែកឱ្យដាច់ក្នុងតុលាការនាពេលអនាគតពីព្រោះ ដូចតុលាការICTYបានទទួលស្គាល់ថា "ប្រសិនបើគេមិនអាចរកឃើញថាជនជាប់ចោទដឹងថា ខ្លួនធ្វើតាមគោលដៅរបស់របបផ្ដាច់ការណាហ្សី នោះតុលាការគួរចាត់ទុកជននោះជាអ្នកជួយ និងទំនុកបម្រុង ព្រោះជននោះគ្មានចេតនាជាក់លាក់"ចង់ប្រព្រឹត្តបទល្មើសនោះដោយឯកឯងទេ"។[17]

២៣. សេចក្ដីសម្រេចដែលបានលើកឡើងដើម្បីគាំទ្រដល់សហកម្មឧក្រិដ្ឋកម្មរួម *ទម្រង់ទី៣* គឺពិតជាភស្ដុតាងដ៏ចម្រូងចម្រាសបំផុតសម្រាប់បង្ហាញពីអត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួម ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ អង្គហេតុទាំងនៅក្នុងករណី *Essen Lynching និង Borkum Island* សុទ្ធតែពាក់ព័ន្ធនឹងហ្វូងមហាជនដែលពោរពេញទៅដោយកំហឹង និងការខកខានមិនបានទប់ស្កាត់ក្នុងព្យសនកម្មដែលអាចប្រមើលមើលដឹងជាមុន។ ទំនាក់ទំនងរវាងអំពើហិង្សាដែលបានប្រព្រឹត្ត និងជនជាប់ចោទមានភាពច្បាស់លាស់បំផុតក្នុងករណី *Essen Lynching* ទោះបីគេគួរកត់សម្គាល់ថា ការគាំទ្រលើសហកម្មឧក្រិដ្ឋកម្មរួម *ប្រសិនបើមានមែន* ក្នុងករណី *Borkum Island* មានលក្ខណៈខ្សោយបន្តិចក្ដី។

២៤. ក្នុងករណី *Essen Lynching* ឈ្លើសសឹកសង្គ្រាមជនជាតិអង់គ្លេសបីនាក់ត្រូវបានគេដាក់ឱ្យហ្វូងមហាជនអាឡឺម៉ង់ ដែលពោរពេញទៅដោយកំហឹងកាត់ទោស។ ក្នុងចំណោមជនជាប់ចោទមានកូនទាហានអាឡឺម៉ង់ ដែលបានស្រែកបញ្ជាក្នុងកម្រិតសម្លេងមួយខ្លាំង ដែលអាចឱ្យហ្វូងមហាជនជនជាតិអាឡឺម៉ង់ឮថា អ្នកការពារអ្នកទោសមិនគួរជ្រែតជ្រែកលើប្រព្រឹត្តកម្មរបស់មហាជនអាឡឺម៉ង់លើអ្នកទោសទេ ព្រោះពួកអ្នកទោសទាំងនោះគួរតែស្លាប់។ ក្នុងចំណោមជនជាប់ចោទក៏មានសមាជិកហ្វូងមហាជនបីនាក់ផងដែរ។ ជាថ្មីម្ដងទៀត ក្នុងករណីនេះ គេត្រូវតែសន្មត់ថាតុលាការបានទទួលស្គាល់ទឡ្ហីករណ៍របស់រដ្ឋអាជ្ញាថា ទោះបីមិនមានភស្ដុតាងប្រាកដប្រជាថា ជនណាម្នាក់ក្នុងចំណោមជនជាប់ចោទទាំងនោះបាននាំឱ្យកើតមាន

[17] សូមមើល ជាពិសេស Stefan Baretzki និងអ្នកដទៃ XXI Justiz und NS-Verbrechen, នៅចំណុច ៨៣៨ និង៨៨១ (Bundesgerichtshof, F.R.G.)។

ព្រឹត្តិការណ៍ដ៏អាក្រក់នោះក៏ដោយ ប៉ុន្តែទំនួលខុសត្រូវរបស់ពួកគេគួរផ្អែកលើអង្គហេតុ ដែលពួកគេរាល់គ្នានោះបានចូលរួមក្នុងទម្រង់ណាមួយក្នុងការធ្វើបាប ដែលទីបំផុតនាំឲ្យជនរងគ្រោះនោះស្លាប់"។[18]

មានបញ្ហាស្នូលសំខាន់ៗពីរក្នុងការប្រើករណីបែបនេះដើម្បីគាំទ្រដល់គោលការណ៍ទូលំទូលាយនៃទម្រង់ទីបីនៃសហកម្មឧក្រិដ្ឋកម្មរួមនេះ ពោលគឺកាលៈទេសៈនៃករណីនេះមិនបង្ហាញឲ្យឃើញច្បាស់ពីតួនាទី និងចេតនារបស់អ្នកចូលរួមនីមួយៗឡើយ ហើយការរកឃើញរបស់តុលាការត្រូវតែទាញចេញពីទឡ្ហីករណ៍របស់រដ្ឋអាជ្ញា និងការរកឃើញកំហុសនៅទីបំផុត។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មានភស្តុតាងមួយចំនួនរួចទៅហើយដើម្បីគាំទ្រដល់អត្ថិភាពជាទូទៅនៃសហកម្មឧក្រិដ្ឋកម្ម*ទម្រង់ទីបី*នេះ នៅក្នុងបណ្តាឆ្នាំដំបូងៗក្រោយសង្គ្រាមលោកលើកទី២។

**២. គោលការណ៍ទូទៅនៃទំនួលខុសត្រូវបុគ្គលផ្អែកលើការប្រព្រឹត្តឧក្រិដ្ឋកម្មរួម**

**ក. យុត្តាធិការនៅក្រៅប្រទេសកម្ពុជា**

២៥. ទំនួលខុសត្រូវលើការចូលរួមក្នុងផែនការរួមមានអត្ថិភាពតាមទម្រង់មួយចំនួន ក្នុងបទប្បញ្ញត្តិច្បាប់ជាតិនៃបណ្តាប្រទេសជាច្រើន យ៉ាងហោចណាស់ក៏តាំងពីសតវត្សរ៍ទី១៩មកម្ល៉េះ។ ទិដ្ឋភាពទូទៅនៃច្បាប់ព្រហ្មទណ្ឌជាតិមួយ ដែលមានលក្ខណៈរួមដូចប្រព័ន្ធច្បាប់នៃបណ្តាប្រទេសដទៃទៀតនោះបង្កើតបានទៅជាមធ្យោបាយគន្លឹះមួយ ដើម្បីពន្យល់ឲ្យឃើញច្បាស់ពីខ្លឹមសារនៃបទដ្ឋានព្រហ្មទណ្ឌអន្តរជាតិថាជាគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ។ សញ្ញាណនៃទំនួលខុសត្រូវបុគ្គលផ្អែកលើផែនការរួម ឬគម្រោងការរួមបានបន្តអភិវឌ្ឍន៍ឈានឡើងក្នុងយុត្តាធិការជាតិនៃបណ្តាប្រទេសទាំងឡាយក្រោយសង្គ្រាមលោកលើកទី២។ វឌ្ឍនភាពក្នុងចំណោមយុត្តាធិការជាតិនៃបណ្តាប្រទេសទាំងនោះ បានបន្តទៅមុខរហូតរួមទាំងក្នុងរយៈពេលពាក់ព័ន្ធ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់អ.វ.ត.កផងដែរ ដូច្នេះហើយវឌ្ឍនភាពទាំងនេះ

[18] សូមមើលករណី *Tadic* កំណត់ជើងទំព័រទី២ កថាខណ្ឌ២០៨ ជើងទំព័រលេខ ២៥៩។

00238331

D99/3/2.5

បានផ្តល់ការគាំទ្របន្ថែមទៀតដល់សញ្ញាណជាទូទៅថា សហកម្មឧក្រិដ្ឋកម្មរួមអាចយកមកអនុវត្តបានជាទម្រង់នៃការទទួលខុសត្រូវមួយនៅចំពោះមុខអ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់១៩៧៩។

២៦. ក្រមព្រហ្មទណ្ឌបារាំង ដែលបានអនុម័តដំបូងនាឆ្នាំ១៨១០ បានប្រមើលមើលឃើញនូវទំនួលខុសត្រូវបុគ្គលចំពោះការចូលរួមគ្នាក្នុងបទឧក្រិដ្ឋមួយ នៅពេលដែលការសន្និដ្ឋានពីការចូលរួមនោះ អាចត្រូវបានស្រាវជ្រាវរកឃើញពីសមាជិកភាពរបស់បុគ្គលនីមួយៗនោះក្នុងក្រុមឧក្រិដ្ឋមួយ។[19] ឧទាហរណ៍មួយស្តីពីទម្រង់នៃការទួលខុសត្រូវបែបនេះមានចែងក្នុងមាត្រា៣១៣ ដែលបានចែងថា បទឧក្រិដ្ឋដែលបុគ្គលបានប្រព្រឹត្ត៖ "*នៅក្នុងការប្រមូលផ្តុំ ដោយមានការបោះបោរ ឬឆក់ប្លន់មិនអាចកាត់ផ្តាច់ចេញពីមេខ្លោង អ្នកប្រព្រឹត្ត អ្នកញុះញង់ និងអ្នកបង្កើតរឿងនៃការប្រមូលផ្តុំទាំងនេះទេ។ ជនទាំងនោះនឹងត្រូវផ្តន្ទាទោសជាពិរុទ្ធជន នៃបទឧក្រិដ្ឋ ឬបទល្មើសទាំងនេះ ហើយត្រូវមានទោសដូចគ្នានឹងអ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះដោយផ្ទាល់ដែរ*" ។[20]

២៧. នៅក្នុងច្បាប់មួយដែលលែងនៅជាធរមានទៀត នៅពេលដែលមានបទល្មើសដែលបានចោទប្រកាន់នៅមុខអ.វ.ត.កនោះ (បន្ទាប់ពីបានលុបចោលនៅក្នុងឆ្នាំ១៩៥៣) ប្រទេសបារាំងបានដោះស្រាយបញ្ហាស្តីអំពី ទំនួលខុសត្រូវក្នុងផែនការ ឬគម្រោងការរួមមួយ និងបានបង្ហាញពីបញ្ហាប្រឈមមួយចំនួនក្នុងការកំណត់ឲ្យបានច្បាស់នូវអត្ថន័យរបស់វា។ ដោយមានការជំរុញបន្ថែមដោយសារឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តនៅក្នុងសង្គ្រាមលោកលើកទី២ ប្រទេសបារាំងបានអនុម័តច្បាប់ *ច្បាប់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៤៨* ដែលបានបង្កើតឲ្យមាននូវការសន្និដ្ឋានមួយលើទំនួលខុសត្រូវបុគ្គលចំពោះបទឧក្រិដ្ឋរួម ដែលទាញចេញពីសមាជិកភាពរបស់ជនទាំងនោះនៅក្នុងក្រុមមួយ ដែលមានគោលដៅក្នុងការប្រដូចសមាជិកភាពនៅក្នុងក្រុមនោះថាជាការចូលរួមក្នុងឧក្រិដ្ឋកម្មនោះតែម្តង។ ច្បាប់ ដែលអស់សុពលភាពនៅថ្ងៃទី

---

[19] ក្រមព្រហ្មទណ្ឌ មាត្រា៣១៣ (១៨១០-១៩៩៤)។

[20] Roger Merle & Andre Vitu, *Traité de Droit Criminel: problèmes généraux de la science criminelle*, 3d ed. (Paris : Editions Cujas, 1978) at 611.

00238332

D99/3/25

៣០ ខែមករា ឆ្នាំ១៩៥៣នោះ បានរកឃើញថា ជនទាំងអស់ដែលជាសមាជិកនៃក្រុមមួយ ដែលត្រូវបានគេប្រកាសថាជាឧក្រិដ្ឋជនដោយតុលាការយោធាអន្តរជាតិនៅNuremberg - ឧទាហរណ៍ ក្រុមយោធា Waffen SS និងក្រុម Gestapo - អាចត្រូវបានគេចោទប្រកាន់ថាជាចារីចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តដោយអង្គការចាត់តាំងនោះ វាលែងតែជនទាំងនេះ ត្រូវបានគេចាប់បញ្ចូលក្នុងអង្គការចាត់តាំងនោះដោយបង្ខំ ឬពួកគេអាចរកភស្តុតាងបង្ហាញពីការមិនបានចូលរួមរបស់ខ្លួននៅក្នុងបទឧក្រិដ្ឋទាំងនោះ។[21] នៅក្នុងមួយរយៈពេលដ៏ខ្លី ដែលច្បាប់ពិសេសនេះនៅជាធរមាន ច្បាប់នេះគឺជាគោលដៅនៃការរិះគន់យ៉ាងខ្លាំងចំពោះការនាំឲ្យមានការរំលោភគោលការណ៍ សិទ្ធិមនុស្សជាសកល ដូចជាគោលការណ៍សច្ចធារណ៍និរទោស នីតិវិធីស្របច្បាប់ និង*គោលការណ៍ គ្មានទោសបើគ្មានច្បាប់ចែងជាដើម*។[22]

២៨. គោលការណ៍អនុវត្តព្រហ្មទណ្ឌរបស់ប្រទេសអ៊ីតាលីមានលក្ខណៈពិសេសដោយឡែក ដែលក្នុងនោះមិនមានការពិពណ៌នាជាបទប្បញ្ញត្តិស្តីពីទម្រង់នៃការចូលរួមទេ។ ទ្រឹស្តីនៃច្បាប់ព្រហ្មទណ្ឌប្រទេសអ៊ីតាលីភាគច្រើនបំផុតគឺផ្តោតជាគោលលើទស្សនទាននៃបទល្មើស ដែលតែងតែត្រូវបានរកឃើញនៅក្រោមទម្រង់នៃការចូលរួមក្នុងយុត្តាធិការច្បាប់ខំមិនឡូ។ ដើមចមពាក់ព័ន្ធដទៃទៀតរួមមាន ការកើតឡើងដំណាលគ្នានៃបទឧក្រិដ្ឋ និងអ្នកចូលរួម ដែលមានចែងក្នុងមាត្រា៨១ និងមាត្រា១១០។[23]

២៩. ទោះបីមាត្រា៨១ចាត់ទុកថាជាស្ថានទម្ងន់មួយក្នុងករណីការកើតឡើងតំណាលគ្នាជាផ្លូវការនៃឧក្រិដ្ឋកម្មទាំងឡាយ ប៉ុន្តែវាក៏បង្ហាញឲ្យឃើញច្បាស់នូវគោលគំនិតថា ជនម្នាក់អាចត្រូវបានចាប់ឲ្យទទួលខុសត្រូវលើពហុភាពនៃបទឧក្រិដ្ឋ ដែលបង្កើតបានជាផ្នែកមួយនៃគម្រោងការឧក្រិដ្ឋរួមតែមួយ (*disegno criminoso*)។ ការស្រាយបំភ្លឺថ្មីៗនេះទៅលើគោលគំនិតនៃ

[21] Frédéric Desportes & Francis Le Gunehec, *Droit pénal general*, 14th ed. (Paris: Economica, 2007) at 481. This was consistent with the presumption under Art. II(1)(d) of Control Council Law No 10 applied in Germany after the Second World War.
[22] Philippe Merle, *Les présomptions légales en droit pénal* (Paris: Librairie Générale de Droit et de Jurisprudence, 1970).
[23] Codice penale, [C.p.] (It.) [unofficial translation].

D99/3/25

បទដ្ឋាននេះបានបង្ហាញឲ្យឃើញថា បន្ទាប់ពីមានកំណែទម្រង់ទៅលើមាត្រាច្បាប់នេះនៅក្នុងឆ្នាំ១៩៧៤ "ការតម្រូវឲ្យមានសភាគភាពនៃអំពើហឹង្សាមានសារសំខាន់យ៉ាងខ្លាំងក្នុងការកំណត់ពីគម្រោងការឧក្រិដ្ឋ ដែលនាបច្ចុប្បន្ននេះត្រូវបានគេពន្យល់ក្នុងន័យអត្តនោមម័តថាជាគំនិត និងជាឆន្ទៈដើម្បីសម្រេចគោលបំណងរួមមួយ ដែលគោលបំណងនោះបំពេញឲ្យការចង់បាននៃកម្មវិធីទូលំទូលាយមួយទៀត។"[24] កំណែទម្រង់នេះកាត់បន្ថយយ៉ាងច្រើននូវសារសំខាន់នៃលក្ខណៈសត្យានុម័តនៃទំនួលខុសត្រូវ (គេយល់ថាជាទំទាក់ទំនងដើមរឿង និងពេលវេលាមួយក្នុងចំណោមបទឧក្រិដ្ឋទាំងឡាយដែលបានប្រព្រឹត្តិ) ហើយបង្ហាញឲ្យឃើញច្បាស់ពីលក្ខណៈអត្តនោមម័ត និងលក្ខណៈចិត្តសាស្ត្រនៃចេតនាឧក្រិដ្ឋនោះថាជាផ្នែកមួយនៃគម្រោងការធំមួយ។[25]

៣០. ផ្ទុយទៅវិញ មាត្រា១១០ ផ្តោតលើចំណោទស្តីពីទំនួលខុសត្រូវផ្ទាល់ខ្លួន ហើយបង្ហាញឲ្យឃើញពីការប្រព្រឹត្តស្រដៀងគ្នាក្នុងពេលតំណាលគ្នា។ យុត្តិសាស្ត្រដែលមានមុនឆ្នាំ១៩៧៥ បានបង្ហាញឲ្យឃើញថារូបមន្តក្នុងមាត្រា១១០ "គ្របដណ្តប់រាល់ទម្រង់ និងគ្រប់កម្រិតទាំងអស់នៃការចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ដែលក្នុងនោះអំពើទាំងឡាយដែលស្តែងចេញពីការសហការនៃក្រុមមនុស្ស និងកម្មវត្ថុទាំងឡាយត្រូវតែចាត់ទុកថាជាអំពើតែមួយ។"[26] នៅពេលយើងអានមាត្រាទាំងពីរនេះជាមួយគ្នា នោះយើងនឹងឃើញថាមាត្រាទាំងនេះបង្ហាញច្បាស់(តាមទ្រឹស្តីព្រហ្មទណ្ឌអ៊ីតាលី)ថា ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ជនម្នាក់អាចត្រូវបានតុលាការចាប់ឲ្យទទួលខុសត្រូវចំពោះទម្រង់ណាមួយ នៃការចូលរួមក្នុងការខិតខំប្រឹងប្រែងរួមមួយ ដែលរួមមានការចូលរួមប្រព្រឹត្តអំពើមួយ ឬច្រើន ដែលបង្កើតបានជាឧក្រិដ្ឋកម្មមួយ ឬច្រើននៅក្នុងក្របខណ្ឌនៃគម្រោងផែនការឧក្រិដ្ឋរួមនោះ។

---

[24] Cass., sez. I, 28 gennaio 1991 – 2 aprile 1991, n. 354, CP 92, 2368 [unofficial translation].

[25] ដូចឯកសារខាងលើ

[26] Cass., sez. I, 4 dicembre 1972 – 24 marzo 1973, n. 2325, GP 73, II 341; CPMA 74, 756 [unofficial translation].

D99/3/25

៣១. ក្រមព្រហ្មទណ្ឌឥណ្ឌាឆ្នាំ១៨៦០ បានដាក់ការទទួលខុសត្រូវជាបុគ្គលចំពោះអំពើខុសច្បាប់ទាំងឡាយណា ដែលបានប្រព្រឹត្តដោយមនុស្សច្រើន សំដៅសម្រេចនូវផែនការរួមមួយ។[27] មាត្រា ៣៤ នៃក្រមព្រហ្មទណ្ឌដើមចែងថា "នៅពេលណាបទឧក្រិដ្ឋមួយត្រូវបានប្រព្រឹត្តឡើងដោយមនុស្សច្រើននាក់ នោះបុគ្គលម្នាក់ៗនៅក្នុងក្រុមនោះត្រូវទទួលខុសត្រូវចំពោះអំពើនោះដូចខ្លួនម្នាក់ៗបានប្រព្រឹត្តដោយខ្លួនឯងដែរ។"[28] បញ្ញត្តិនេះត្រូវបានធ្វើវិសោធនកម្មមុនឆ្នាំ១៩៧៥ ដើម្បីបញ្ចូលនូវការបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់ថា អំពើនោះត្រូវតែធ្វើឡើងសំដៅសម្រេចនូវចេតនារួម។ ដូច្នេះ នាពេលបច្ចុប្បន្ននេះ បញ្ញត្តិនេះសរសេរថា "នៅពេលណាបទឧក្រិដ្ឋមួយត្រូវបានប្រព្រឹត្តឡើងដោយមនុស្សច្រើននាក់ សំដៅសម្រេចគោលបំណងរួមនៃអ្នកទាំងអស់គ្នា នោះបុគ្គលម្នាក់ៗនៅក្នុងក្រុមនោះត្រូវទទួលខុសត្រូវចំពោះអំពើដែលបានកើតឡើងនោះ ដូចខ្លួនម្នាក់ៗបានប្រព្រឹត្តដោយខ្លួនឯងដែរ។"[29]

៣២. ប្រទេសកាណាដាដាក់ការទទួលខុសត្រូវដូចគ្នានេះដែរចំពោះការចូលរួមក្នុងផែនការរួម ហើយបទប្បញ្ញត្តិច្បាប់នៃប្រទេសនេះផ្តល់នូវការគាំទ្រយ៉ាងខ្លាំង ជាពិសេសចំពោះអត្ថិភាពនៃសហកម្មឧក្រិដ្ឋកម្មរួមនៅមុនឆ្នាំ១៩៧៥។ មាត្រា៦១(២) នៃក្រមព្រហ្មទណ្ឌកាណាដាឆ្នាំ១៨៩៣ ចែងថា៖

> ប្រសិនបើជនច្រើននាក់បង្កើតនូវចេតនារួមមួយ ដើម្បីអនុវត្តនូវគោលបំណងខុសច្បាប់ណាមួយ និងដើម្បីជួយគ្នាទៅវិញទៅមកក្នុងក្រុមនោះ ជនម្នាក់ៗក្នុងចំណោមជនទាំងនោះគឺជាភាគីមួយទៅនឹងរាល់បទល្មើសទាំងឡាយ ដែលបានប្រព្រឹត្តដោយជនណាម្នាក់ក្នុងចំណោមជនទាំងនោះក្នុងការអនុវត្តន៍នូវគោលបំណងរួមនោះ ដែលការប្រព្រឹត្តនូវបទល្មើសនោះត្រូវបានដឹង ឬគួរតែបានដឹងអំពីផលវិបាកដែលអាចកើតមានពីការអនុវត្តន៍នៃគោលបំណងនោះ។

[27] Walter Morgan and A.G. MacPherson, *Indian Penal Code*, (XLV, 1860) (London: G.C. Hay & Co. 1861).

[28] ដូចឯកសារខាងលើ

[29] ករណី Matiullah Sheikh ទល់នឹង រដ្ឋBengalខាងលិច ឆ្នាំ១៩៦៤ S.C.R (6) 978។

00238335

D99/13/25

៣៣. បទបញ្ញត្តិនេះត្រូវបានកែប្រែដូចក្នុងមាត្រា២១(២)នៅក្នុងឆ្នាំ១៩៧០ ហើយតុលាការកាណាដាបានដាក់ទណ្ឌកម្មលើការទទួលខុសត្រូវក្នុងផែនការរួមតាម*ក្រមព្រហ្មទណ្ឌ*នោះ។[30] ក្នុងករណី *R ទល់នឹង Trinneer* ជនជាប់ចោទបានចូលរួមក្នុងផែនការរួមមួយដើម្បីប្រព្រឹត្តអំពើប្លន់ជាមួយសហចារីម្នាក់ ដែលនាំទៅដល់ការធ្វើឃាតលើជនរងគ្រោះ។[31] ទោះបីការចូលរួមរបស់ជនជាប់ចោទត្រឹមតែការអង្គុយនៅក្នុងឡានរបស់ជនរងគ្រោះក៏ដោយ ជនជាប់ចោទនេះបានដឹងថាគូកនរបស់ខ្លួនមានកាំបិតមុតស្រួច ដែលក្រោយមកទៀតគូកនរបស់ខ្លួននោះបានប្លន់និងចាក់សម្លាប់ជនរងគ្រោះនៅក្រៅឡាននោះ។ ទោះជាយ៉ាងណាក៏ដោយ ជនជាប់ចោទបានដឹងថាគូកនរបស់ខ្លួនមានកាន់កាំបិតមុតស្រួចមុនពេលប្រព្រឹត្តិអំពើប្លន់និងសម្លាប់នោះ។ តុលាការបានសម្រេចថាការកាត់ឱ្យជនជាប់ចោទ នេះជាប់ពិរុទ្ធពីបទមនុស្សឃាតដោយប្រយោលគឺជាការត្រឹមត្រូវ ព្រោះជនជាប់ចោទនេះបានដឹងនូវ អត្ថិភាពនៃកំបិតមុតស្រួចដូច្នោះហើយ លទ្ធភាពនៃការចាក់សម្លាប់ពិតជាអាចកើតមានឡើងក្នុងការប្រព្រឹត្តអំពើប្លន់នោះ។[32]

៣៤. នៅក្នុងសេចក្តីសម្រេចគួរឱ្យកត់សម្គាល់នៅក្នុងរឿងក្តី *Tadic* តុលាការICTY បាន យោងលើរឿងក្តីឆ្នាំ១៩៤៦របស់តុលាការកំពូលសហរដ្ឋអាមេរិក ដែលសេចក្តីសម្រេចនេះត្រូវបានគេចាត់ទុកជាការចាប់ផ្តើមនូវទម្រង់នៃការទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងសហរដ្ឋអាមេរិក។ ជាដំបូង តុលាការជម្រះរឿងក្តី *Tadic* បានយោងលើទ្រឹស្តីក្នុងសេចក្តីសម្រេចរឿងក្តី*Pinkerton តទល់នឹង សហរដ្ឋអាមេរិក* ឆ្នាំ១៩៤៦ របស់តុលាការកំពូលសហរដ្ឋអាមេរិកដែលកាលបរិច្ឆេទសម្រេចរឿងក្តីនេះកើតឡើងមុនអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩។[33] តុលាការជម្រះរឿងក្តី *Tadic* បានកត់សម្គាល់ត្រឹមត្រូវថា ទ្រឹស្តីនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលកើតចេញមកពីផែនការឬគម្រោងការណ៍រួម មិនមានចែងនៅក្នុងបទប្បញ្ញត្តិ

[30] មាត្រា២១(២) នៃក្រមព្រហ្មទណ្ឌ R.S.C. 1970, C.C-34។

[31] [1970] S.C.R. 638។

[32] *ដូចឯកសារខាងលើ។* ( In Canada this notion has also been questioned. As discussed *infra*, the Supreme Court of Canada later placed constitutional restrictions on the degree of liability that can be imposed on individuals for crimes committed by others in furtherance of a common plan where these acts constitute specific-intent crimes such as attempted murder); see *R. v. Logan*, [1990] 2 S.C.R. 731.

[33] រឿងក្តី *Pinkerton តទល់នឹង សហរដ្ឋអាមេរិក* 328 U.S. 640 (1946) [Pinkerton]។

D99/3/25

ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិកទេ ទោះបីជាទ្រឹស្តីនេះត្រូវបានគេយកមកបកស្រាយនៅតាមរដ្ឋនានាក្តី។[34] រឿងក្តី *Pinkerton* មានអង្គហេតុពាក់ព័ន្ធនឹងបង/ប្អូនប្រុសពីរនាក់ ដែលត្រូវបានគេចោទប្រកាន់អំពីបទល្មើសទាក់ទងនឹងពន្ធជាច្រើន រួមមានការចោទប្រកាន់លើបុគ្គលម្នាក់ៗអំពីបទសមគំនិតផងដែរ។ Pinkerton ត្រូវបានគេចោទប្រកាន់ទាំងបទល្មើសសមគំនិតប្រព្រឹត្តអំពើលួចពន្ធជាមួយបង/ប្អូនប្រុសរបស់គាត់ ព្រមទាំងចោទប្រកាន់គាត់អំពីបទល្មើសលួចពន្ធមួយចំនួនដែលបង/ប្អូនប្រុសរបស់គាត់បានប្រព្រឹត្ត រួមទាំងអំពើមួយចំនួនដែលបង/ប្អូនប្រុសរបស់គាត់បានប្រព្រឹត្ត ក្នុងអំឡុងពេលគាត់ជាប់ក្នុងមន្ទីរឃុំឃាំងផងដែរ។ តុលាការកំពូលបានសម្រេចថា យើងមិនចាំបាច់បង្ហាញថាPinkertonបានចូលរួមដោយផ្ទាល់ចំពោះបទល្មើសដែលកើតឡើងនោះទេ ប៉ុន្តែវាជាការគ្រប់គ្រាន់ក្នុងការបង្ហាញថា បទល្មើសដែលកើតឡើងដោយសារកិច្ចព្រមព្រៀងខុសច្បាប់ គឺជាផលវិបាកដែលអាចដឹងជាមុន។ ក្នុងករណីនេះ Pinkertonនឹងទទួលខុសត្រូវព្រហ្មទណ្ឌផ្ទាល់ចំពោះបទល្មើសដែលកើតឡើងនោះ។[35] ជាលទ្ធផល Pinkertonត្រូវបានតុលាការសម្រេចឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលកើតឡើងដោយការប្រព្រឹត្តរបស់បង/ប្អូនប្រុសគាត់។[36] ក្រោយពីការ

---

[34] រឿងក្តី Tadic សូមមើលខាងលើនៅជើងទំព័រលេខ២ កថាខណ្ឌ២២៤ ជើងទំព័រ២៨៩ (ដកស្រង់ចេញពី Maine (ក្រមព្រហ្មទណ្ឌ17 Maine ផ្នែកទី៥៧ (១៩៩៧), Minnesota (ច្បាប់Minnesota ផ្នែកទី៦០៩.០៥ (១៩៩៨)), Iowa (ក្រមIowa ផ្នែកទី៧០៣.២ (១៩៩៧)), Kansas (ច្បាប់Kansas ផ្នែក២១-៣២០៥ (១៩៩៧)), Wisconsin (ច្បាប់Wisconsin ផ្នែកទី៩៣៩.០៥ (West 1995))។ យ៉ាងហោចណាស់ច្បាប់ចំនួនពីរ (ច្បាប់មកពីMinnesota និងច្បាប់មកពីWisconsin) បានចូលជាធរមាននៅឆ្នាំ១៩៧២។ Wayne R. LaFave & Austin W. Scott Jr., *ច្បាប់ព្រហ្មទណ្ឌ* (Minnesotaៈ បោះពុម្ពផ្សាយនៅWest ឆ្នាំ១៩៧២) នៅចំណុចទី៥១៤ កំណត់សម្គាល់ទី៨ [LaFave & Scott]។ ច្បាប់Minnesota រួមបញ្ចូលជនសមគំនិតជាមួយអ្នកផ្សេងទៀតដើម្បីប្រព្រឹត្តបទល្មើស នៅពេលច្បាប់Wisconsin ចែងអំពីជន "ដែលជាភាគីនឹងជនសមគំនិតដើម្បីប្រព្រឹត្តបទល្មើស" ដូចមានខាងលើ។

[35] *Pinkerton សូមមើលខាងលើ*នៅជើងទំព័រលេខ៣៣ នៅចំណុច៦៤១-៦៤២។ សូមមើលផងដែរ LaFave & Scott *សូមមើលខាងលើ*នៅជើងទំព័រលេខ៣៤ នៅចំណុច៥១៣ (រៀបរាប់អំពីលក្ខខណ្ឌនៅក្នុងច្បាប់សហរដ្ឋអាមេរិកអំពីការចោទប្រកាន់សំខាន់ៗអំពីបទល្មើសដែលមិនបានប្រព្រឹត្តដោយចុងចោទ ប៉ុន្តែកើតឡើងដោយផលវិបាកដែលអាចដឹងជាមុននៃគម្រោងផែនការខុសច្បាប់)។

[36] *Pinkerton សូមមើលខាងលើ*នៅជើងទំព័រលេខ៣៣ នៅចំណុច៦៤២។

សម្រេចនេះ សេចក្តីសម្រេចរបស់Pinkerton ត្រូវបានគេប្រើប្រាស់ក្នុងការដាក់បន្ទុកលើចុងចោទឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលអ្នកផ្សេងទៀតប្រព្រឹត្ត។[37]

៣៥. ផ្អែកតាមការទទួលខុសត្រូវជាទូទៅចំពោះបទល្មើសដែលអាចដឹងជាមុន ទោះបីជាស្ថិតនៅខាងក្រៅវិសាលភាពនៃគម្រោងការណ៍ច្បាស់លាស់ក៏ដោយ ការទទួលខុសត្រូវរបស់ *Pinkerton* ហាក់ដូចជាស្រដៀងគ្នានឹងទម្រង់ទីបីរបស់សហឧក្រិដ្ឋកម្មរួម។ ដោយសារតែកត្តាពេលវេលាក្នុងរឿងក្តី*Pinkerton* និងរឿងក្តី*Tadic* អាចយកមកប្រើប្រាស់ចំពោះ អ.វ.ត.ក ក៏ប៉ុន្តែសេចក្តីសម្រេចរបស់*Pinkerton* កំពុងត្រូវបានគេរិះគន់។ សេចក្តីសម្រេចនេះក្លាយជាមូលដ្ឋានខ្វែងគំនិតគ្នាចំពោះការលើកឡើងថា ច្បាប់សហរដ្ឋអាមេរិកនៅពេលនោះគាំទ្រទម្រង់នៃការទទួលខុសត្រូវ ដែលពាក់ព័ន្ធនឹងទម្រង់ទីបីរបស់សហឧក្រិដ្ឋកម្មរួម។[38] នៅក្នុងសំណេររបស់LaFave & Scottកាលពីទសវត្សឆ្នាំ១៩៧០បានពន្យល់ថាអ្នកទាំងឡាយដែលពង្រាងនូវក្រមព្រហ្មទណ្ឌគំរូដែលមានឥទ្ធិពលយ៉ាងខ្លាំងនៅសហរដ្ឋអាមេរិក បានកត់សម្គាល់ថា "ច្បាប់នឹងបាត់បង់អស់នូវស្មារតីយុត្តិធម៌ ប្រសិនបើជនណាមួយអាចត្រូវបានសម្រេចឱ្យទទួលខុសត្រូវចំពោះបទល្មើសរាប់ពាន់ ដែលជននោះមិនមានឥទ្ធិពលលើវាទាល់តែសោះ"។[39] LaFave & Scott បានបង្ហាញបន្ថែមទៀតថា សេចក្តីសម្រេចរបស់*Pinkerton* "មិនដែលទទួលបានការគាំទ្រភាគច្រើនឡើយ" ដោយបន្ថែមថា ការជំទាស់នឹងសេចក្តីសម្រេចនេះ បានកើនឡើងចាប់តាំងពីដើមទសវត្សឆ្នាំ១៩៧០។[40] ពីដំបូង ដោយសារការដាក់ការទទួលខុសត្រូវបែបនេះមានលក្ខណៈទូលំទូលាយពេក LaFave & Scottបានកត់សម្គាល់ថា

---

[37] *LaFave & Scott សូមមើលខាងលើនៅជើងទំព័រលេខ៣៤ នៅចំណុច៥១៣។*

[38] *សូមមើលខាងលើ។*

[39] *សូមមើលខាងលើ។ (ដកស្រង់ចេញពីក្រមព្រហ្មទណ្ឌគំរូ ផ្នែកទី២.០៤, មតិយោបល់ (សេចក្តីពង្រាង១ ឆ្នាំ១៩៥៣))។*

[40] *សូមមើលខាងលើ នៅចំណុច៥១៥។*

D99/3/25

សេចក្តីសម្រេចរបស់*Pinkerton* ត្រូវបានអ្នកពង្រាងក្រមព្រហ្មទណ្ឌគំរូបដិសេធចោល និង មិនមានចែងនៅក្នុងក្រមព្រហ្មទណ្ឌសហព័ន្ធទេ។[41]

៣៦. ទ្រឹស្តីដែលមានលក្ខណៈស្រដៀងគ្នាមួយទៀតនៅក្នុងច្បាប់សហរដ្ឋអាមេរិក អាចចេញមកពី "វិធានឃាតកម្មជាយថាហេតុ ដែលកើតក្នុងពេលប្រព្រឹត្តបទល្មើស"របស់ច្បាប់កូមិនឡូ។ វិធាននេះចែងអំពីការដឹងជាមុននូវបទល្មើសដែលកើតចេញពីផែនការឧក្រិដ្ឋកម្មរួម។ ទ្រឹស្តីដែលមានតាំងពីមុនទសវត្សឆ្នាំ១៩៧០ បានកំណត់ឲ្យចុងចោទទទួលខុសត្រូវចំពោះបទល្មើសដែលអាចដឹងជាមុន ពីព្រោះបទល្មើសនេះគឺជាផលវិបាកដែលអាចដឹងជាមុន ដែលជននោះមានបំណងជួយ ឬលើកទឹកចិត្តឲ្យប្រព្រឹត្ត។"[42] វិធាននេះត្រូវបានគេរិះគន់ជាយូរមកហើយ និងនៅតែទទួលការរិះគន់ក្នុងទសវត្សឆ្នាំ១៩៧០ ដោយសារតែវិធាននេះអនុញ្ញាតឲ្យមានការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋមួយ ដែលចេតនាឧក្រិដ្ឋនោះមានលក្ខណៈផ្សេងពីចេតនានៃឧក្រិដ្ឋដែលបានគិតទុកជាមុន។[43] វិធានឃាតកម្មជាយថាហេតុដែលកើតក្នុងពេលប្រព្រឹត្តបទល្មើស បានកម្រិតត្រឹមឃាតកម្មដែលកើតឡើង នៅខណៈពេលដែលជនសមគំនិតបានចូលរួមយ៉ាងសកម្មក្នុងការប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរផ្សេងទៀត។[44] ទោះជាយ៉ាងណាក៏ដោយ យើងកត់សម្គាល់ឃើញថា ទោះបីជាវិធាននេះមានចែងជាយូរមកហើយនៅក្នុងច្បាប់កូមិនឡូ

[41] *សូមមើលខាងលើ។* (ដកស្រង់ចេញពីមតិយោបល់ជាតិស្តីពីកំណែទម្រង់ច្បាប់ព្រហ្មទណ្ឌសហព័ន្ធ ឯកសារពាក់ព័ន្ធពី ១៥៥ ដល់១៥៧ (១៩៧០)។ មតិយោបល់ជាតិស្តីពីកំណែទម្រង់ច្បាប់ព្រហ្មទណ្ឌសហព័ន្ធ របាយការណ៍បញ្ចប់ ដែលស្នើឡើងដោយក្រមព្រហ្មទណ្ឌសហព័ន្ធថ្មី ផ្នែក៤០១ (១៩៧១))។ សូមមើល Allison Marston Danner & Jenny S. Martinez, *Guilty Association○: សហកម្មឧក្រិដ្ឋកម្មរួម, ការទទួលខុសត្រូវដោយបញ្ជា និងការវិវឌ្ឍន៍របស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (២០០៥) ៩៣ Cal. L. Rev. 75 នៅចំណុច១៤០ (កត់សម្គាល់ថា ការរិះគន់មួយចំនួនអំពីចំណុចទទួលខុសត្រូវPinkerton ចំពោះករណីដែលឲ្យជនណាមួយទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលមិនមានចេតនាប្រព្រឹត្ត ប៉ុន្តែគ្រាន់តែអាចដឹងជាមុន ដែលបង្កើតឲ្យមានមូលដ្ឋានមិនយុត្តិធម៌) [Marston & Martinez]។

[42] LaFave & Scott *សូមមើលខាងលើ*នៅជើងទំព័រលេខ៣៤ នៅចំណុច៥១៥ ដល់៥១៦។

[43] សូមមើលខាងលើ។

[44] សូមមើលខាងលើ។

ប៉ុន្តែវិធាននេះត្រូវបាននិរាករណ៍នៅក្នុងរដ្ឋជាច្រើន និងការលុបចោលនូវសញ្ញាណនេះបានកំពុងតែកើតឡើង នៅពេលបទល្មើសនានានៅចំពោះមុខអ.វ.ត.កត្រូវប្រព្រឹត្តិ។[45]

៣៧. តុលាការប្រទេសអង់គ្លេស ក៏បានគូសបញ្ជាក់ស្រដៀងគ្នានេះដែរ ចំពោះភាពអាចមើលឃើញជាមុននេះ មុននឹងធ្វើការសម្រេចថាតើការទទួលខុសត្រូវជាបុគ្គលចំពោះការប្រព្រឹត្តបទឧក្រិដ្ឋក្នុងអំឡុងពេលសហកម្មឧក្រិដ្ឋកម្មរួមអាចអនុវត្តបាន ឬមិនមាននោះ។ នៅក្នុងរឿងក្តី *R ទល់នឹង Smith (Wesley)* ជនជាប់ចោទបានចូលរួមប្រព្រឹត្តជាមួយជនបីនាក់ផ្សេងទៀតក្នុងគោលបំណងរួមគ្នាបំផ្លិចបំផ្លាញបានីយដ្ឋានមួយកន្លែង។[46] ការចូលរួមប្រព្រឹត្តជាក់ស្តែងរបស់ជនត្រូវចោទមានកម្រិតត្រឹមតែគប់ដុំថ្មចូលក្នុងបានីយដ្ឋាន ប៉ុន្តែគាត់បានដឹងថាសហចារីម្នាក់របស់គាត់មានកាន់កាំបិត។ សហចារីរូបនោះបានប្រើកាំបិតទៅសម្លាប់អ្នកក្រឡុកស្រានៅក្នុងបានីយដ្ឋាននោះ។ ជនជាប់ចោទត្រូវបានផ្តន្ទាទោសពីបទមនុស្សឃាត ដោយផ្អែកតាមទ្រឹស្តីថា ឃាតកម្មស្ថិតនៅក្នុងវិសាលភាពនៃផែនការរួមចំពោះការវាយប្រហារទៅលើបានីយដ្ឋាននោះ ហើយផលវិបាកនៃទង្វើនេះអាចដឹងជាមុនបាន។

### ខ. វត្តមានភាពក្នុងច្បាប់កម្ពុជា

៣៨. ច្បាប់ព្រហ្មទណ្ឌជាធរមានក្នុងអំឡុងពេលពាក់ព័ន្ធ គឺក្រមព្រហ្មទណ្ឌនិងច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលបោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌របស់ព្រះរាជាណាចក្រកម្ពុជា។[47] រហូត

[45] សូមមើលខាងលើ។ សូមមើលផងដែរនូវ *Commonwealth ex rel. Smith តទល់នឹង Myers,* 261 A.2d 550 (Pa. 1970)។ រឿងក្តី *State តទល់នឹង Branson,* 487 N.W.2d 880 (Minn. 1992)។

[46] [1963] 3 All E.R. 597។

[47] ក្រមព្រហ្មទណ្ឌ និងច្បាប់ព្រហ្មទណ្ឌ បោះពុម្ពផ្សាយដោយក្រសួងយុត្តិធម៌របស់ព្រះរាជាណាចក្រកម្ពុជា [ក្រមព្រហ្មទណ្ឌកម្ពុជា]។

មកទល់ឆ្នាំ១៩៧៥ គ្មានប្រភពជឿជាក់ណាមួយបង្ហាញអំពីការវិវឌ្ឍន៍នៃច្បាប់នេះទេ និងគ្មានច្បាប់យុត្តិសាស្ត្របកស្រាយលម្អិតអំពីបញ្ហានេះទេ។[48]

៣៩. គ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ ចែងអំពីសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ទេ។ ផ្នែកមួយចំនួននៃក្រមព្រហ្មទណ្ឌកម្ពុជានេះ បានចែងអំពីបង្ហាញទាក់ទងនឹងផែនការរួម។ ឧទាហរណ៍ មាត្រា៨២ នៃមាតិកាការចូលរួមប្រព្រឹត្តជាមួយចែងថា "ជនណាចូលរួមប្រព្រឹត្តដោយចេតនានូវឧក្រិដ្ឋកម្ម ទោសកម្មណាមួយ ដោយផ្ទាល់ក្តី ដោយប្រយោលក្តី ជននោះត្រូវមានទោសដូចជាអាទិចារី។"[49] ទ្រឹស្តីនៃផែនការរួមនេះមាននៅក្នុងមាត្រា៨៣ រហូតដល់មាត្រា៨៧ ដោយចែងថា ការរួមប្រព្រឹត្តដោយប្រយោលឬដោយសមគំនិត នឹងអាចមានទោសបាន ក៏លុះតែអំពើនោះបានសម្រេចមកពីការនាំអាទិ៍ ការឲ្យអនុទ្ទេស ការផ្តល់មធ្យោបាយ ការជួយ ឬការទំនុកបំរុង។[50]

### ៣. វឌ្ឍន៍ភាពច្បាប់បន្ថែមទៀត និងការរែកញែកលម្អិត

៤០. ខណៈពេលយុត្តាធិការជាតិនៃបណ្តាប្រទេសទាំងឡាយបានបន្តអភិវឌ្ឍសញ្ញាណ នៃការទទួលខុសត្រូវព្រហ្មទណ្ឌដោយផ្អែកលើផែនការរួមក្រោយពីសង្គ្រាមលោកលើកទីពីរ សញ្ញាណនេះត្រូវបានអនុវត្តក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិបច្ចុប្បន្ន នៅក្នុងសេចក្តីសម្រេចរឿងក្តី *Tadic* របស់តុលាការICTY។ ក្រោយមក សេចក្តីសម្រេចរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានសម្រិតសម្រាំងបន្ថែមទៀតលើទម្រង់នៃការទទួលខុសត្រូវនេះ។

---

[48] ក្រុមជំនាញរបស់ប្រទេសកម្ពុជា *របាយការណ៍ក្រុមជំនាញរបស់ប្រទេសកម្ពុជា បង្កើតឡើងដោយយោងនឹងសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ ៥២/១៣៥,* UN GAOR សម័យប្រជុំទី៥៣ ឯកសារអង្គការសហប្រជាជាតិ S/ 1999/231 & A/53/850 (1999)។

[49] ក្រមព្រហ្មទណ្ឌ *សូមមើលខាងលើ*នៅជើងទំព័រលេខ៤៧ នៅមាត្រា៨២។

[50] ដូចមានខាងលើ មាត្រា៨៣-៨៧។

00238341

D99/3/25

៤១. ចាប់តាំងពីមានការណែនាំអំពីទ្រឹស្តីនៃសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងសេចក្តីសម្រេច រឿងក្តី *Tadic* របស់តុលាការកំពូល ទ្រឹស្តីនេះទទួលការរិះគន់យ៉ាងខ្លាំងពីសំណាក់អ្នកសិក្សាជាន់ខ្ពស់[51] និងចុងចោទចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ ការខ្វែងគំនិតគ្នាអំពីការអនុវត្តទ្រឹស្តីនេះ បានលើកឡើងនៅក្នុងច្បាប់យុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀត។[52] ការខ្វែងគំនិតគ្នាជុំវិញទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម គឺស្ថិតនៅលើភាពមិនច្បាស់លាស់នៃធាតុផ្សំផ្នែកច្បាប់របស់វា លើ*គោលការណ៍គ្មានទោសប្រសិនគ្មានច្បាប់ចែង* និងលើសិទ្ធិនានារបស់ចុងចោទ។

៤២. ទោះបីអង្គជំនុំជម្រះសាលាឧទ្ធរណ៍ លើឡើងពីទម្រង់ទាំងបីនៃសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងរឿងក្តី *Tadic*ក្តី ក៏អង្គហេតុនៅក្នុងរឿងក្តី *Tadic*នេះ ស៊ីគ្នាតែជាមួយនឹងទម្រង់ទីបីនៃការចូលរួមប្រព្រឹត្ត ដែលជាទម្រង់ដ៏ចម្រូងចម្រាស់ប៉ុណ្ណោះ។ ដូច្នេះ ការដែល គោលការណ៍សហកម្មឧក្រិដ្ឋកម្មរួមតែងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទម្រង់មិនសូវផ្ទាល់ នៃសហកម្មឧក្រិដ្ឋកម្មរួមនោះ

---

[51] សូមមើលឧទាហរណ៍ Alexander Zahar & Goran Sluiter, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ*០: ការណែនាំនូវការរិះគន់មួយ (Oxford: OUP, 2007) នៅចំណុច២២១-២៥៧។ Machteld Boot, *បទល្មើសប្រល័យពូជសាសន៍, បទល្មើសប្រឆាំងមនុស្សជាតិ, បទល្មើសសង្គ្រាម:* គ្មានទោសប្រសិនគ្មានច្បាប់ចែង និងកម្មវត្ថុយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (Antwerpen: Intersentia, ២០០២) នៅចំណុច២៨៨-៣០៤។ Jens David Ohlin "បញ្ហាទស្សនៈចំនួនបីទាក់ទងនឹងទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម" (២០០៧) ៥ J. Intl Crim. J. 69។ Kai Ambos "សហកម្មឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវដោយបញ្ជា" (២០០៧) ៥ J. Intl Crim. J. ១៥៩។ Elies van Sliedregt "សហកម្មឧក្រិដ្ឋកម្មរួមជាវិធីផ្តន្ទាទោសចំពោះបុគ្គលពីបទល្មើសប្រល័យពូជសាសន៍" (២០០៧) ៥ J. Intl Crim. J. ១៨៤។

[52] សូមមើលឧទាហរណ៍ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brdanin* សំណុំរឿងលេខ IT-៩៩-៣៦-A សេចក្តីសម្រេចរបស់តុលាការកំពូល មតិយោបល់ជំទាស់មួយផ្នែករបស់ចៅក្រមShahabuddeen (ថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧) (ICTY)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Martic* សំណុំរឿងលេខ IT-៩៥-១១-A សេចក្តីសម្រេចរបស់តុលាការកំពូល មតិយោបល់ដាច់ដោយឡែករបស់ចៅក្រម Schomburg ស្តីអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គលនៃ Milan Martic (ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨) (ICTY)។ ប្រៀបធៀបផងដែរអំពីវិធីផ្សេងគ្នានៃអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Static* សំណុំរឿងលេខ IT-៩៧-២៤ សេចក្តីសម្រេចរបស់សាលាដំបូង (ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣) នៅកថាខណ្ឌទី៤៣១-៤៤២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Stakic* សំណុំរឿងលេខ IT-៩៧-២៤-A សេចក្តីសម្រេចរបស់តុលាការកំពូល (ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦) នៅកថាខណ្ឌទី៥៨-៦៣។

អាចជាហេតុនាំឱ្យគេយកទម្រង់ទីបីនេះមកប្រើប្រាស់ដំបូងតែម្តង។ ប្រសិនបើតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានពិចារណាលើសហកម្មឧក្រិដ្ឋកម្មទម្រង់ទី១ ឬសហកម្មឧក្រិដ្ឋកម្មទម្រង់ទី២ ហើយតាមរយៈនោះបង្កើតនូវមូលដ្ឋានសម្រាប់សហកម្មឧក្រិដ្ឋកម្មទម្រង់ទី៣នោះ ម្ល៉េះទស្សនទាននៃទម្រង់ទីបីនេះអាចមានន័យកាន់តែចង្អៀត និងវចនាសម្ព័ន្ធមិនស្មុគស្មាញខ្លាំងទេ។ ប៉ុន្តែផ្ទុយមកវិញ បច្ចុប្បន្ននេះ សហកម្មឧក្រិដ្ឋរួមទទួលនូវការរិះគន់យ៉ាងខ្លាំង។[53]

៤៣. ការរិះគន់សហកម្មឧក្រិដ្ឋកម្មរួម មានសូម្បីតែក្នុងយុត្តិសាស្ត្ររបស់តុលាការICTY។ ឧទាហរណ៍ ក្រោយពីបដិសេធចោលសាលក្រមនៅក្នុងបណ្តឹងឧទ្ធរណ៍ ចៅក្រមLindholm បានរិះគន់ដោយផ្តល់យោបល់ផ្ទាល់ខ្លួនគាត់នៅក្នុងរឿងក្តី Simic ថា៖

> ខ្ញុំសូមដកខ្លួនចេញពីទស្សនៈឬទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងរឿងក្តីនេះ និងរឿងក្តីដទៃទៀតជាទូទៅ។ ចំពោះទស្សនៈរបស់ខ្ញុំ ទម្រង់មូលដ្ឋាននៃសហកម្មឧក្រិដ្ឋកម្មរួមមិនមានធាតុផ្សំណាមួយរបស់ខ្លួននោះទេ។ សហកម្មឧក្រិដ្ឋកម្មរួមគ្រាន់តែជាទម្រង់ថ្មីមួយភ្ជាប់ទៅនឹងទស្សនៈ ឬទ្រឹស្តីមួយដែលគេបានស្គាល់ជាយូរមកហើយនៅក្នុងយុត្តិសាស្ត្រជាច្រើន ព្រមទាំងនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ថាជាការប្រព្រឹត្តបទឧក្រិដ្ឋរួមគ្នា។ ប្រសិនបើមិនមានការប្រព្រឹត្តណាមួយផ្សេងពីការប្រព្រឹត្តក្នុងទម្រង់ជាសហចារីទេ ដូច្នេះការចាត់ទុកទម្រង់នៃការប្រព្រឹត្តិរួមនេះចូលក្នុងទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនេះ នាំឱ្យមានជម្លោះរវាងទ្រឹស្តីនេះនិងពាក្យ "បានប្រព្រឹត្ត" នៅក្នុងមាត្រា ៧(១) របស់ច្បាប់លក្ខន្តិកៈ។[54]

---

[53] នៅក្នុងអត្ថបទថ្មីមួយ លោកAntonio Cassese បានយោងទៅលើទម្រង់បីនៃការទទួលខុសត្រូវ ដែលទម្រង់ទី១៖ "ការទទួលខុសត្រូវចំពោះគោលបំណងចេតនារួម" ទម្រង់ទី២៖ "ការទទួលខុសត្រូវចំពោះការចូលរួមប្រព្រឹត្តនៅក្នុងផែនការឧក្រិដ្ឋរួមជាស្ថាប័ន" និងទម្រង់ទី៣៖ "ការទទួលខុសត្រូវព្រហ្មទណ្ឌដោយផ្អែកលើការសន្មត់ទទួលយកភយន្តរាយដោយបានដឹងជាមុន និងដោយស្ម័គ្រចិត្ត។" ដកស្រង់ចេញពីច្បាប់យុត្តិសាស្ត្រក្រោយៗ Cassese បានស្នើឱ្យបកស្រាយ និងកម្រិតនូវដែនកំណត់របស់JCE ដោយសារតែJCEមានដើមកំណើតវិវត្តន៍ចេញពីរឿងក្តី Tadic៖ Antonio Cassese "ការកំណត់ឱ្យបានសមស្របចំពោះការទទួលខុសត្រូវរបស់បុគ្គលក្រោមទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម" (២០០៧) ៥ J. Intl Crim. J. ១០៩។

[54] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Simic et al.* សំណុំរឿងលេខ IT-៩៥-៩-T សេចក្តីសម្រេចរបស់សាលាដំបូង មតិយោបល់ដាច់ដោយឡែក និងដោយផ្នែករបស់ចៅក្រម Per-Johan Lindholm (ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣) នៅកថាខណ្ឌទី២។

៤៤. ការរិះគន់របស់Machteld Boot ចំពោះសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ គឺតំណាងឲ្យការយល់ឃើញក្នុងទ្រឹស្តីអនុវត្តមួយ។ គាត់បានរៀបរាប់អំពីរបៀបអង្គជំនុំជម្រះតុលាការកំពូលត្រលប់មកប្រើច្បាប់ទំនៀមទំលាប់អន្តរជាតិក្នុងគោលបំណងកំណត់ចេតនាឧក្រិដ្ឋ និងអំពើឧក្រិដ្ឋចំពោះបទឧក្រិដ្ឋរួម ដែលមានចែងក្នុងមាត្រា៧(១) នៃច្បាប់លក្ខន្តិកៈរបស់តុលាការICTY។[55] លោកBoot មិនជំទាស់នឹងការបកស្រាយរបស់អង្គជំនុំជម្រះចំពោះសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី១ និងទម្រង់ ទី២ទេ ប៉ុន្តែគាត់បានពិភាក្សាវែកញែកអំពីការខ្វែងគំនិតគ្នាជាយូរមកហើយជុំវិញសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣។ គាត់បានរៀបរាប់អំពីសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូលថា "សញ្ញាណនៃគម្រោងការរួមជាការទទួលខុសត្រូវសមគំនិត ត្រូវបានរកឃើញយ៉ាងច្បាស់នៅក្នុងទំនៀមទម្លាប់អន្តរជាតិថា "មិនមានភាពប្រាកដនិយម"ទេ។[56] Boot យល់ឃើញថា ក) សញ្ញាណនេះផ្អែកលើរឿងក្តីមួយចំនួនតូចតែប៉ុណ្ណោះ ខ) រឿងក្តីរបស់តុលាការក្នុងស្រុក ដែលអង្គជំនុំជម្រះសាលាដំបូងដកស្រង់មកមិនមានលក្ខណៈឯកភាពគ្នាគ្រប់គ្រាន់ទេ គ) និងច្បាប់ជាតិដែលចែងអំពីទម្រង់ទទួលខុសត្រូវថ្មីនោះ មិនបានបញ្ចូល"ច្បាប់មនុស្សធម៌អន្តរជាតិ" ដូចដែលរបាយការណ៍ស្តីអំពីច្បាប់លក្ខន្តិកៈតុលាការICTYរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិផ្តល់អនុសាសន៍ឲ្យនោះទេ។[57] បន្ថែមពីលើនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ផ្អែកលើសន្ធិសញ្ញាចំនួនពីរ (អនុសញ្ញាអន្តរជាតិស្តីពីការគាបសង្កត់ទៅលើការដាក់គ្រាប់បែករបស់ភេរវជន និងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម) ដែលសន្ធិសញ្ញាទាំងពីរនេះចូលជាធរមានបន្ទាប់ពីរឿងក្តី *Tadic*។

---

[55] Machteld Boot, បទល្មើសប្រល័យពូជសាសន៍ បទល្មើសប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម៖ គ្មានទោសប្រសិនបើគ្មានច្បាប់ និងកម្មវត្ថុយុត្តាធិការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (Antwerpen: Intersentia, ២០០២) នៅចំណុចទី២៧២។ យោងតាមច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅមាត្រា៧, វិបសាយICTY (http://www.un.org/icty/legaldoce/basic/statut/statute-feb08-e.pdf)។

[56] Boot *សូមមើលខាងលើ*នៅជើងទំព័រលេខ៥៥ នៅចំណុច២៧៤។

[57] ដូចខាងលើ នៅចំណុច៣៦។

៤៥. មតិរិះគន់ដដែរៗចំពោះសហកម្មឧក្រិដ្ឋកម្មរួមគឺថា "សហកម្មឧក្រិដ្ឋកម្មរួមខ្វះនូវនិយមន័យច្បាស់ ក្នុងការកំណត់ឲ្យបានច្បាស់អំពីវិសាលភាព នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល។"[58] តាមពិតធាតុផ្សំសហកម្មឧក្រិដ្ឋកម្មរួម ដែលបកស្រាយនៅក្នុងសាលដីកាករណី *Tadic* មានភាពមិនច្បាស់លាស់ជាច្រើន ទាក់ទងនឹងលក្ខណៈផែនការឬគោលបំណងរួមដែលបានព្រមព្រៀង និងទំនាក់ទំនងរវាងផែនការឬគោលបំណងរួមជាមួយនឹងបទល្មើសដែលបានប្រព្រឹត្តទាក់ទងនឹងផែនការរួមនេះ។

៤៦. អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការICTY បានទទួលស្គាល់ថា ភាពមិនច្បាស់លាស់របស់សហកម្មឧក្រិដ្ឋរួមបានបង្កើតនូវក្ដីកង្វល់ជាច្រើនទាក់ទងនឹងគោលការណ៍យុត្តិធម៌៖

> ច្បាប់លក្ខន្តិកៈមិនមានចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌអ្វី ក្រៅពីទម្រង់នៃការចូលរួមប្រព្រឹត្តដែលចែងយ៉ាងច្បាស់នៅក្នុងច្បាប់នោះទេ។ ជាពិសេស ការសម្រេចឲ្យជនជាប់ចោទទទួលខុសត្រូវ ចំពោះការទទួលខុសត្រូវណាមួយ ដែលមិនមានចែងច្បាស់នៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺជាការមិនចាំបាច់ និងមិនយុត្តិធម៌ទេ។[59]

៤៧. នៅក្នុងរឿងក្ដីថ្មីៗជាច្រើន ជាពិសេសរឿងក្ដី*Brdjanin* និង*Martic* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានព្យាយាមឆ្លើយតបទៅនឹងក្ដីកង្វល់ទាំងពីរនេះ និងបកស្រាយពន្យល់អំពីធាតុផ្សំសហកម្មឧក្រិដ្ឋកម្មរួម។ លើកលែងតែចៅក្រមSchomburgចេញ ក្រៅពីនោះមតិយល់ស្រប

---

[58] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Limaj et al.,* សំណុំរឿងលេខ IT-០៣-៦៦-A សេចក្ដីសម្រេចរបស់តុលាការកំពូល ផ្នែកនៃមតិយោបល់ជំទាស់ និងមតិយោបល់ដោយឡែក និងសេចក្ដីប្រកាសរបស់ចៅក្រម Schomburg (ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧) (តុលាការICTY) កថាខណ្ឌទី១០។

[59] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Bagilishema* សំណុំរឿងលេខ ICTR-៩៥-១A-A សេចក្ដីសម្រេចរបស់តុលាការកំពូល (ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០២) កថាខណ្ឌទី៣៤។

00238345

D99/3/25

គ្នាភាគច្រើននៃអង្គចៅក្រម បានលើកឡើងនៅក្នុងអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY ថាសហកម្មឧក្រិដ្ឋកម្មរួមគួរតែយកមកប្រើប្រាស់ជាទម្រង់នៃការទទួលខុសត្រូវ។[60]

៤៨. ចុងចោទ និងអ្នកអត្ថាធិប្បាយជាច្រើន បានលើកឡើងថាទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមមានវិសាលភាពត្រឹមតែ"កំហុសព្រោះមានការពាក់ព័ន្ធ" តែប៉ុណ្ណោះ។ ជាការពិតណាស់ ទ្រឹស្តីនេះបានបង្កើតឡើងនូវបញ្ហាជាច្រើនអំពីវិសាលភាពដ៏ត្រឹមត្រូវនៃការទទួលខុសត្រូវ និងសិទ្ធិរបស់ចុងចោទ។ យើងនឹងពិភាក្សាម្តងមួយៗអំពីបញ្ហាទាក់ទងនឹងកម្រិតបទដ្ឋាននៃធាតុផ្សំចេតនា និងវិសាលភាពរបស់សហកម្មឧក្រិដ្ឋកម្មរួម។ យើងនឹងពិភាក្សាផងដែរលើលក្ខខណ្ឌនៃការចូលរួមប្រព្រឹត្ត។

<u>បញ្ហាទាក់ទងនឹងកម្រិតបទដ្ឋាននៃចេតនាឧក្រិដ្ឋ</u>

៤៩. កម្រិតបទដ្ឋានធាតុផ្សំចេតនាទាប នៃសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ទី៣ធ្វើឱ្យមានភាពចម្រូងចម្រាស់យ៉ាងខ្លាំង ព្រោះចុងចោទត្រូវបានសម្រេចឱ្យទទួលខុសត្រូវចំពោះចេតនាជាក់លាក់ក្នុងការប្រព្រឹត្តបទល្មើសដែលចោទប្រកាន់ នៅពេលចុងចោទអាចគ្រាន់តែធ្វេសប្រហែសប៉ុណ្ណោះ។ មានន័យថា ការអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម"ទម្រង់ពង្រីក"ចំពោះបទល្មើសដែលមានចេតនាជាក់លាក់បានបន្ថយកម្រិតធាតុផ្សំចេតនា ដែលធ្វើឱ្យមានការប៉ះទង្គិចជាមួយតម្រូវការលក្ខខណ្ឌចេតនាបន្ថែមចំពោះបទល្មើសមួយចំនួន។ សហកម្មឧក្រិដ្ឋកម្មរួម បានសាកល្បងពិនិត្យមើលវិឃិតភាពនៃចេតនា ដែលជាកត្តាសំខាន់ក្នុងការកំណត់ពីទំនួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសធ្ងន់ធ្ងរនានា។ ជាលទ្ធផល សហកម្មឧក្រិដ្ឋកម្មរួម"ទម្រង់ពង្រីក" ជាទម្រង់មានលក្ខណៈងាយស្រួលក្នុងការផ្តន្ទាទោសអ្នកចូលរួមដោយប្រយោល ជាជាងផ្តន្ទាទោសចារី។ ដោយឈរលើគោលការណ៍នេះ ប្រព័ន្ធព្រហ្មទណ្ឌក្នុងប្រទេសមួយចំនួន ដូចជាប្រទេសអាឡឺម៉ង់ ប្រទេសហូឡង់ និងប្រទេសស្វីស មិនបានចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួម "ទម្រង់ពង្រីក" ជាទម្រង់នៃការចូលរួមប្រព្រឹត្តទៀតទេ។ សូម្បីនៅក្នុងយុត្តាធិការនៃប្រទេស

[60] សូមមើលរឿងក្តី *Martic, សូមមើលខាងលើ*នៅជើងទំព័រលេខ៥២ កថាខណ្ឌ១៦៨ ដល់កថាខណ្ឌ១៧៣ (នៅពេលតុលាការកំពូលស្វែងរកមូលដ្ឋាននៃអំណាចជាក់ច្បាស់ពីរឿងក្តី*Stakic និង Brdnin)*។

ដែលទទួលស្គាល់ទ្រឹស្តីនេះដូចជាកាណាដា សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ក៏ទ្រឹស្តីនេះត្រូវបានទទួលការរិះគន់យ៉ាងខ្លាំងដែរ។[61]

៥០. ចាប់តាំងពីអង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការICTYបានចេញសេចក្តីសម្រេច ក្នុងករណី *Brdjanin* ដែលតុលាការនេះបានយល់ឃើញថា សហកម្មឧក្រិដ្ឋកម្មរួម“ទម្រង់ពង្រីក” អាចអនុវត្តបានចំពោះបទល្មើសដែលមានចេតនាជាក់លាក់ ដូចជាបទល្មើសប្រល័យពូជសាសន៍ជាដើមនោះ[62] បញ្ហានេះនៅតែមានការខ្វែងគំនិតគ្នាយ៉ាងខ្លាំង។[63] នៅក្នុងរឿងក្តី*Brdjanin* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការរកឃើញថា សហកម្មឧក្រិដ្ឋកម្មរួម “ទម្រង់ពង្រីក” មិនអាចយកមកអនុវត្តចំពោះបទល្មើសប្រល័យពូជសាសន៍បានទេដោយសារតែសហកម្មឧក្រិដ្ឋកម្មរួម“ទម្រង់ពង្រីក” បានបន្ថយនូវលក្ខខណ្ឌធាតុផ្សំចេតនារបស់បទល្មើសប្រល័យពូជសាសន៍ពី “ចេតនារួមដើម្បីបំផ្លាញក្រុមមួយ” ទៅជាការបំផ្លិចបំផ្លាញក្រុមមួយ“ជាធម្មតា និងដែលអាចប្រមើលមើលឃើញជាមុន”។[64]

៥១. ពួកអ្នករិះគន់ចំពោះសេចក្តីសម្រេចរបស់*Brdjanin* បានលើកឡើងថា ដូចបទល្មើសមានចេតនាជាក់លាក់ផ្សេងទៀតដែរ លក្ខខណ្ឌសំខាន់បំផុតរបស់បទល្មើសប្រល័យពូជសាសន៍គឺ“ធាតុផ្សំចេតនាជាក់លាក់”របស់វា។ ការលុបបំបាត់នូវធាតុផ្សំនេះ ឲ្យស្មើគ្នានឹងធាតុផ្សំនៃ

---

[61] *Marston & Martinez សូមមើលខាងលើ*នៅជើងទំព័រលេខ៤១ នៅចំណុច៣២។

[62] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brdanin* សំណុំរឿងលេខ IT-៩៩-៣៦-A, សេចក្តីសម្រេចលើសាលក្រមរបៀប (ថ្ងៃទី៩ ខែមីនា ឆ្នាំ២០០៤) (តុលាការICTY)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milosevic* សំណុំរឿងលេខ IT-០២-៥៤-T សេចក្តីសម្រេចលើបណ្តឹងចំពោះការសម្រេចសុំឲ្យរួចខ្លួន (ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤) (តុលាការICTY)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karemera, Ngirumpatse, Nzirorera, Rwamakuba,* សំណុំរឿងលេខICTR-៩៨-៤៤-T សេចក្តីសម្រេចរបស់សាលាដំបូង (ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៤) នៅកថាខណ្ឌទី៤៦។

[63] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kvocka et al.,* សំណុំរឿងលេខ IT-៩៨-៣០/១ សេចក្តីសម្រេចលើបណ្តឹងបឋមដោយមេធាវីការពារក្តី តវ៉ានឹងយុត្តាធិការទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួម (ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០១) នៅកថាខណ្ឌទី២៨។

[64] *រឿងក្តី Brdanin* សេចក្តីសម្រេចលើសាលក្រមរបៀប *សូមមើលខាងលើ*នៅជើងទំព័រលេខ៦២។

"កំហុសចំពោះការចូលរួមប៉ុន្តែមិនបានប្រព្រឹត្តបទល្មើសដោយផ្ទាល់" គឺជាការរំលោភលក្ខខណ្ឌតម្រូវឱ្យបង្ហាញពីចេតនាបន្ថែម ដែលមានចែងនៅក្នុងច្បាប់លក្ខន្តិកៈរបស់តុលាការអន្តរជាតិ។ មេធាវីបានលើកឡើងថា លក្ខខណ្ឌបន្ថែមចំពោះបទល្មើសប្រល័យពូជសាសន៍គឺជា "ការបន្ថែម" ប៉ុន្តែមិនមែន "ជាការការពារទុកជាមុន" ចំពោះលក្ខខណ្ឌទទួលខុសត្រូវរបស់បុគ្គលទេ ដូច្នេះសហកម្មឧក្រិដ្ឋកម្មរួម"ទម្រង់ពង្រីក" គឺគ្មានអ្វីផ្សេងគ្នាពីទម្រង់ចូលរួមប្រព្រឹត្តផ្សេងទៀតនៃបទល្មើសប្រល័យពូជសាសន៍ទេ។[65] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី*Krstic* បានយល់ឃើញថា ការផ្តន្ទាទោសបទល្មើសប្រល័យពូជសាសន៍ដោយផ្អែកលើសហកម្មឧក្រិដ្ឋកម្មរួម តម្រូវឱ្យមានភស្តុតាង"ច្បាស់លាស់" នៃចេតនាពិតប្រាកដ ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដូច្នេះតុលាការស្នើឡើងថា បញ្ហាទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួមមិនទាន់ត្រូវបានដោះស្រាយទេ។[66] តាមពិត អ្នកអត្ថាធិប្បាយបានបកស្រាយសេចក្តីសម្រេចរបស់តុលាការកំពូលក្នុងរឿងក្តី*Krstic* ដែលលើកឡើងអំពី "បញ្ហាពាក់ព័ន្ធមួយចំនួននៃការទទួលខុសត្រូវព្រហ្មទណ្ឌជំនួស នៅក្នុងបរិបទនៃសហកម្មឧក្រិដ្ឋកម្មរួមរបស់បទល្មើសប្រល័យពូជសាសន៍។"[67]

<u>បញ្ហាទាក់ទងនឹងវិសាលភាពនៃគម្រោងការឧក្រិដ្ឋ</u>

៥២. របៀបកំណត់វិសាលភាពសហកម្មឧក្រិដ្ឋកម្ម គឺជាឆន្ទានុសិទ្ធិរបស់រដ្ឋអាជ្ញាទាំងស្រុង លើកលែងតែសហកម្មឧក្រិដ្ឋកម្មទម្រង់ទី២ ដែលវិសាលភាពនៃទម្រង់នេះកម្រិតត្រឹមតែបទឧក្រិដ្ឋប្រព្រឹត្តនៅក្នុងជំរុំប៉ុណ្ណោះ។[68] ឆន្ទានុសិទ្ធិនេះមានភាពចម្រូងចម្រាស់យ៉ាងខ្លាំង ពីព្រោះ

---

[65] *រឿងក្តី Karemera សូមមើលខាងលើ*នៅជើងទំព័រលេខ៤៦។

[66] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstic* សំណុំរឿងលេខ IT-៩៨-៣៣-A សេចក្តីសម្រេចតុលាការកំពូល (ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤) (តុលាការICTY) កថាខណ្ឌទី ១៣៤។

[67] Mark A. Drumbl, "អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការICTY បានសម្រេចលើរឿងក្តីសំខាន់ពីរ៖ *រឿងក្តី Blaskic និង រឿងក្តីKrstic"* ASIL Insights (ខែកក្កដា ឆ្នាំ២០០៤), វិបសាយ ASIL (www.asil.org/insights/insigh143.htm)។

[68] *Marston & Martinez សូមមើលខាងលើ*នៅជើងទំព័រលេខ៤១។

បើឲ្យនិយមន័យគម្រោងផែនការនេះកាន់តែទូលាយ ការចូលរួមប្រព្រឹត្តកាន់តែច្រើនទំនងជាស្ថិតក្នុងវិសាលភាពសហកម្មឧក្រិដ្ឋកម្មរួមជាមិនខាន។ អ្នកដឹងជ្រៅជ្រះផ្នែកច្បាប់ព្រហ្មទណ្ឌអន្តរជាតិមួយចំនួន បារម្ភថា "ឆន្ទានុសិទ្ធិរដ្ឋអាជ្ញា ដែលមិនមែនជាការអនុវត្តក្នុងនាមបុគ្គលក្លាយជាការកំណត់ដ៏សំខាន់ក្នុងការពង្រីក នៃការធ្វើខុសដែលចោទប្រកាន់ចំពោះបុគ្គលចុងចោទនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម។"[69] ប៉ុន្តែ ការប្រើប្រាស់ឆន្ទានុសិទ្ធិរដ្ឋអាជ្ញាក្នុងការកំណត់វិសាលភាព "បានទទួលការគាំទ្រយ៉ាងខ្លាំង" នៅក្នុងច្បាប់ព្រហ្មទណ្ឌជាតិរបស់សហរដ្ឋអាមេរិក។[70] ប្រព័ន្ធច្បាប់ព្រហ្មទណ្ឌជាតិនៃប្រទេសមួយចំនួន មានបំណងដោះស្រាយនូវភាពមិនច្បាស់លាស់នេះតាមរយៈការកំណត់លើវិសាលភាព ដែលតម្រូវឲ្យរដ្ឋអាជ្ញាបង្ហាញថាផែនការរួម "មាននិរន្តរភាពទាំងរចនាសម្ព័ន្ធនិងចរិតលក្ខណៈ" ជាជាងគ្រាន់តែបង្ហាញថា "ជនជាប់ចោទដែលពាក់ព័ន្ធក្នុងសកម្មភាពនោះ ត្រឹមតែមានគោលបំណងរួម។"[71]

៥៣. សេចក្ដីសម្រេចរបស់តុលាការយោធាអន្តរជាតិ បានបកស្រាយយ៉ាងទូលាយអំពីវិសាលភាពរបស់សហកម្មឧក្រិដ្ឋកម្មរួម។ តុលាការបានសម្រេចថា ក្រុម ឬអង្គការចាត់តាំងដែលមានផែនការរួម សន្និសីទញឹកញាប់រវាងមន្ត្រីបុគ្គលិកជាមួយនឹងអ្នកបញ្ជានៅសមរភូមិ និងការសម្របសម្រួលទាំងមូល មិនគ្រប់គ្រាន់ដើម្បីបង្កើតជាសហកម្មឧក្រិដ្ឋកម្មរួមទេ។ គោលបំណងនិងគោលដៅឧក្រិដ្ឋនៃផែនការរួម ត្រូវតែមានច្បាស់លាស់ មានន័យថាបុគ្គលដែលជាភាគីនៃផែនការដែលចោទប្រកាន់ ត្រូវតែដឹង ឬត្រូវបានសន្មតថា បានដឹងអំពីគោលបំណងគម្រោងផែនការនោះ។

៥៤. តុលាការយោធាអន្តរជាតិបានសម្រេចថា ផែនការរួម ឬការសមគំនិត "ត្រូវតែពន្យល់ឲ្យបានច្បាស់ចំពោះគោលបំណងឧក្រិដ្ឋរបស់វា។ ពេលវេលានៃការសម្រេចចិត្តប្រព្រឹត្ត មិនត្រូវឃ្លាតគ្នាឆ្ងាយពេកនឹងពេលវេលាប្រព្រឹត្តទេ។[72] មាត្រា៩ នៃធម្មនុញ្ញNuremberg បានផ្ដល់

[69] ដូចខាងលើដែរ។

[70] ដូចខាងលើដែរ ចំណុច៦៤។

[71] *រឿងក្ដីសហរដ្ឋអាមេរិក តទល់នឹង Bledsoe,* 674F. 2d 647 (C.A. Mo. 1982)។

[72] *រឿងក្ដី France et al. តទល់នឹង Goering et al.,* (១៩៤៦) ២២ IMT ៤១១; ៤១ A.J.I.L. ១៧២។

អំណាចឲ្យតុលាការក្នុងការសម្រេចថា ក្រុម ឬអង្គការចាត់តាំងមួយ គឺជាអង្គការចាត់តាំងឧក្រិដ្ឋកម្ម ឬមិនមែន។ អនុភាពនៃការអនុញ្ញាតឲ្យតុលាការមានសិទ្ធិសម្រេចលើភាពឧក្រិដ្ឋបែបនេះបានជួយបន្ថយបន្ទុកភស្តុតាងរបស់រដ្ឋអាជ្ញា។

៥៥. ជាក់ស្តែង គ្រាន់តែមានសមាជិកភាពនៅក្នុងអង្គការចាត់តាំងឧក្រិដ្ឋកម្មក្នុងសមត្ថភាពជាអ្នកដឹកនាំគឺគ្រប់គ្រាន់ដើម្បីនាំជននោះមកចំពោះមុខតុលាការ។ ប៉ុន្តែ តុលាការបានគូសបញ្ជាក់អំពីការអនុវត្តន៍នូវលក្ខខណ្ឌយុត្តិធម៌។ ទោះបីមានសមាជិកភាពនៅក្នុងអង្គការចាត់តាំងឧក្រិដ្ឋកម្ម បង្កើតជាមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់ និងជួយកបន្ថយបន្ទុកភស្តុតាងរបស់ខាងអយ្យការក្តី ប៉ុន្តែភាពជាសមាជិកតែមួយមិនគ្រប់គ្រាន់ក្នុងការផ្តន្ទាទោសបុគ្គលនោះទេ។ ជនត្រូវចោទមានសិទ្ធិក្នុងការបង្ហាញថា ពួកគេមិនបានដឹងអំពីគោលបំណង ឬការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់អង្គការ ឬបង្ហាញថាពួកគេត្រូវបានបង្ខំឲ្យចូលជាសមាជិកភាពដោយគ្មានជម្រើសអ្វីទាំងអស់។[73]

៥៦. បន្ទាប់ពីតុលាការប្រកាសអំពីការសម្រេចនៃការរកឃើញអំពើឧក្រិដ្ឋ តុលាការបានរកឃើញថា នៅរបបណាហ្សីអាឡឺម៉ង់ អគ្គសេនាធិការ និងបញ្ជាការជាន់ខ្ពស់ និងគណៈរដ្ឋមន្ត្រីReich មិនស្ថិតក្នុងករណីសហកម្មឧក្រិដ្ឋកម្មរួមទេ ទោះបីជាបុគ្គលនីមួយៗនៅក្នុងក្រុមរបស់ពួកគេអាចត្រូវបានគេរកឃើញថាមានកំហុសអំពីអំពើឧក្រិដ្ឋក្តី។ ប៉ុន្តែ កងយោធា Gestapo និង SS ត្រូវបានតុលាការសម្រេចឲ្យជាប់ពីបទសហកម្មឧក្រិដ្ឋកម្មរួម ដោយសារតែគោលបំណងបឋមរបស់ក្រុមទាំងនេះពាក់ព័ន្ធនឹងសកម្មភាពឧក្រិដ្ឋ។[74]

[73] ដូចខាងលើដែរ ចំណុច៥០០។ Quincy Wright "ច្បាប់អន្តរជាតិ និងកំហុសចំពោះការចូលរួមប៉ុន្តែមិនបានប្រព្រឹត្តបទល្មើសដោយផ្ទាល់" (១៩៤៩) ៤៣ A.J.I.L.៧៤៦ ចំណុចទី៧៥៤។ H. Donnedieu de Vabrez "Le process de Nuremberg devant les principes modernes du droit penal international" (១៩៤៧) ៧០ Rec. des Cours ៤៨៣ ចំណុចទី៥៤៣-៥៨។

[74] *រឿងក្តីFrance et al., សូមមើលខាងលើ*នៅជើងទំព័រលេខ៧២ ចំណុចទី៥០០។

00238350

D99/3/25

<u>បញ្ហាទាក់ទងនឹងលក្ខខណ្ឌនៃការចូលរួមប្រព្រឹត្ត</u>

៥៧. លក្ខខណ្ឌនៃការចូលរួមប្រព្រឹត្តនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម មិនទាន់ត្រូវគេបានដោះស្រាយនោះទេ។ ទោះបីករណី*Kvocka* បានបង្ហាញថា សកម្មភាពរបស់ចុងចោទ "តាមមធ្យោបាយណាមួយ..........ត្រូវតែជាការជួយជំរុញសំដៅសម្រេចផែនការឬគោលបំណងរួមនោះក្តី" វានៅមិនទាន់ច្បាស់ថាតើ "ការចូលរួមប្រព្រឹត្តតិចតួចនៅក្នុងសហកម្មឧក្រិដ្ឋកម្មរួម គ្រប់គ្រាន់ដើម្បីដាក់បុគ្គលនោះឲ្យទទួលខុសត្រូវសហកម្មឧក្រិដ្ឋកម្មដែរឬទេ។"[75] ទោះបីជាអង្គជំនុំជម្រះសាលាដំបូងរបស់តុលាការICTY បានណែនាំអំពីលក្ខខណ្ឌនៃការចូលរួមប្រព្រឹត្ត"ជាដុំកំភួន" ក៏ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលមិនទាន់ឯកភាពលើនិយមន័យនេះទេ។[76] ទ្រឹស្តីវិទូមួយចំនួនគាំទ្រនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង អំពីការប្រើប្រាស់លក្ខខណ្ឌនេះ។[77] បញ្ហានេះមានការខ្វែងគំនិតគ្នាយ៉ាងខ្លាំង នៅពេលអនុវត្តចំពោះមន្ត្រីមានឋានន្តរសក្តិទាប ដែលតួនាទីតូចតាចរបស់ពួកនោះអាចត្រូវបានគេបកស្រាយឲ្យទទួលខុសត្រូវព្រហ្មទណ្ឌក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួម។[78]

---

[75] *រឿងក្តី Kvocka សូមមើលខាងលើ*នៅជើងទំព័រលេខ៦៣ កថាខណ្ឌទី២៨៩។ *រឿងក្តីMarston & Martinez សូមមើលខាងលើ*នៅជើងទំព័រលេខ៤១។

[76] *រឿងក្តី Marston & Martinez សូមមើលខាងលើ*នៅជើងទំព័រលេខ៤១ ចំណុចទី៥៩។ *រឿងក្តីKvocka សូមមើលខាងលើ*នៅជើងទំព័រលេខ៦៣ ចំណុចទី៣០៩, ៣១១។ *រឿងក្តីSimic សូមមើលខាងលើ*នៅជើងទំព័រលេខ៥៤ កថាខណ្ឌទី១៥៩។

[77] *រឿងក្តីMarston & Martinez សូមមើលខាងលើ*នៅជើងទំព័រលេខ៤១ ចំណុចទី៣។

[78] ដូចខាងលើដែរ ចំណុចទី៦០។

D99/3/25

## ៥. សេចក្តីសន្និដ្ឋាន

យោងតាមការវិភាគខាងលើ អ្នកមិនមែនជាភាគីក្នុងរឿងក្តីយល់ឃើញថា ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមត្រូវបានគេទទួលស្គាល់ ក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិក្នុងអំឡុងពេលពាក់ព័ន្ធ (១៩៧៥-១៩៧៩)។ ដូចនេះ អ.វ.ត.ក.អាចយកទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមមកអនុវត្តនៅក្នុងករណីចំពោះមុខនេះ ដោយមិនផ្ទុយនឹង *គោលការណ៍គ្មានទោសប្រសិនគ្មានច្បាប់ចែងទេ*។ តុលាការគួរចងចាំថា គោលការណ៍នេះក៏អាចអនុញ្ញាតឲ្យជនជាប់ចោទទទួលបានអត្ថប្រយោជន៍ពីវឌ្ឍនភាពច្បាប់ក្រោយៗ ចំពោះអំពើដែលកំពុងរងការចោទប្រកាន់នេះផងដែរ។ ក្នុងន័យនេះ សហកម្មឧក្រិដ្ឋកម្មរួមអាចជាសញ្ញាណល្អសម្រាប់ជនជាប់ចោទ។ នេះគឺជាបញ្ហាដែលត្រូវដេញដោលនៅក្នុងដំណាក់កាលជំនុំជម្រះលើអង្គសេចក្តី ជាជាងនៅក្នុងដំណាក់កាលមុនអង្គសេចក្តី ហេតុដូច្នេះហើយចំនុចនេះមិនត្រូវបានលើកឡើងនៅទីនេះ។

សាស្ត្រាចារ្យ Rene Provost
ប្រធានមជ្ឈមណ្ឌលMcGill ដើម្បីសិទ្ធិមនុស្ស និងពហុច្បាប់